Pharmacy Rewards of 2017/2018: We distributed the 15% pharmacy reward to the stakeholders (based on adherence and patient satisfaction) in all OD’s. This 15% is the share of the turnover in the public health facilities from the sales of the medicines of our Revolving Drug Fund. This sharing of revenue with the public service has been going on since 6 years and we see a rising trend in adherence and in patient satisfaction. It is a sort of public private partnership but then not-for-profit. Over the years the system has gained confidence of those who work in it. It is financially sustainable and the patients pay the full cost of their own routine medication including insulin and syringes. Feedback was positive and we felt good support for our program from our counterparts.

TV’s : We bought 10 LG TV’s (43 inch) to install in HC’s and Ref Hospitals for showing health promotion video’s.

Peer Educators training: During 2018, a total of 12 candidate peer educators were trained and passed the exam: Some replace peer educators that have deceased. First 4 for Kampong Speu province and 1 from Niroth HC, Bassac OD and then 5 (4 K.Thom and 1 K.Speu). Then 2 candidates, at the end of the year also passed the exam, both from Baseth district in Kampong Speu.

ការរៀបចំផ្ទៃក្នុងរបស់អង្គការ ម.ព.ជ MoPoTsyo's internal organization

ប្រជុំប្រចាំត្រីមាស៖ យើងបានរៀបចំឱ្យមានការប្រជុំនាចុងត្រីមាសនីមួយៗ ដើម្បីពិនិត្យមើលវឌ្ឍនភាពការងារក្នុងត្រីមាស និងកែសម្រួលផែនការសម្រាប់ត្រីមាសបន្ទាប់។ តាមរយៈការប្រជុំ យើងបានពិនិត្យមើលរួមគ្នាក្នុងចំនោមបុគ្គ លិកការិយាល័យរបស់អង្គការ ទៅលើផែនការរបស់ពេលខ្លី និងវែង និងបានពិភាក្សាលើបញ្ហា និងដំណោះស្រាយនាត្រីមាសឬឆ្នាំបន្ទាប់។

ប្រជុំប្រចាំឆ្នាំ២០១៨៖ យើងបានរៀបចំប្រជុំប្រចាំឆ្នាំ ២០១៨ នាខេត្តសៀមរាបពីថ្ងៃទី២៦ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា។ វាជាឱកាសដ៏រីករាយ ដោយបានវត្តមានចូលរួមពីសមាជិកក្រុមប្រឹក្សាភិបាលចំនួន០២រូប ក្នុងនោះមានវត្តមានប្រធានក្រុមប្រឹក្សាភិបាល លោក មែន ឈានរិទ្ធ និងវេជ្ជបណ្ឌិត គី កាណារី។ ជាការកត់សំគាល់ ការប្រជុំចំនួន០២ថ្ងៃពិតជាមិនគ្រប់គ្រាន់។ យើងបានសម្រេចថា នឹងប្រើពេល០៣ថ្ងៃ សម្រាប់ការប្រជុំប្រចាំឆ្នាំ នាពេលបន្ទាប់ទៀត ដោយជ្រើសរើសយកខេត្តកំពត នាឆ្នាំក្រោយ។

បង់ប្រាក់ប្រាក់បៀវត្សជាប្រាក់រៀល៖ វាគឺជា រឿងសមហេតុសមផល ក្នុងការប្រើប្រាស់មូលដ្ឋានជាប្រាក់រៀល និងឈប់យកប្រាក់ដុល្លារអាមេរិកមូលដ្ឋាន។ ឆ្នាំ២០១៨ ជាឆ្នាំទីមួយ ដែលប្រាក់ខែរបស់បុគ្គលិកការិយាល័យទាំង៣១នាក់ គឺជាប្រាក់រៀលចាប់ពីខែមករា។ រាល់ប្រតិបត្តិការថវិកាទាំងអស់ត្រូវធ្វើតាមរយៈធនាគារដោយអង្គការម.ព.ជ មិនប្រើសាច់ប្រាក់សុទ្ធ ឬសែកឡើយ។

ម៉ាស៊ីនមន្ទីរពិសោធន៍វេជ្ជសាស្ត្រថ្មី៖ យើងបានទិញម៉ាស៊ីន HumaStar200 ពីប្រទេសអាឡឺម៉ង់ សម្រាប់ការវិភាគ គេស្តជីវគីមីសាស្ត្រ នៅក្នុងមន្ទីរពិសោធន៍វេជ្ជសាស្ត្ររបស់យើង។ វាជាការដាក់ទុនដ៏ធំមួយ ប៉ុន្តែវានឹងរួមចំណែកក្នុងការសន្សំថ្លៃចំណាយដោយសារវាជាម៉ាស៊ីនស្វ័យប្រវត្តិ។ យើងបានចាប់ផ្តើមដំណើរការម៉ាស៊ីនថ្មីនេះ នាសប្តាហ៍ទីបួននៃខែឧសភា និងវាបានជួយសម្រួលបន្ទុកការងាររបស់បុគ្គលិកយើង។

ការចំណាយកើនឡើង៖ យើងបានព្យាបាលស្វែងរកការផ្គត់ផ្គង់រាល់សម្ភារបរិក្ខាទាំងអស់ពីក្រុមហ៊ុន និងហាងដែលមានពន្ធលើតម្លៃបន្ថែមត្រឹមត្រូវតាមច្បាប់កំណត់។ មួយវិញតែយើងបានទិញប័ណ្ណធានារ៉ាប់រងសុខភាព និងគ្រោះថ្នាក់ការងារពីរបបសន្តិសុខសង្គម(បសស) សម្រាប់បុគ្គលិក និងមិត្តអប់រំមិត្តឱ្យស្របតាមការកំណត់ដោយច្បាប់ការងារថ្មី។ កត្តាទាំងនេះ បានធ្វើឱ្យចំណាយមានការកើនឡើង។

Quarterly Meetings: At the end of every quarter, we reviewed the progress to adjust the plan for the rest of the year. The meeting was held with most of our salaried employees from 10.30 until 17.00 at the 3rd floor of our office. We were able to review our short term and long term objectives, and discuss problems that must be solved to improve the flow.

Annual Staff Retreat 2018: was held in Siem Reap from 26 till 30 November. It was very productive and pleasant. Two members of the Board were present this year: both our President Mr Men Cheanrithy and Dr Ky Kanary. 2 days of meetings was not enough so a 3rd day will be added next year which will be in Kampot.

Salary payments from USD to Cambodian Riels: It made sense to change our main currency from USD to Cambodian Riels. 2018 is the first year that we pay all 31 staff employees in Riels, starting with January. Payments are done through ACLEDA Bank, internet banking. MoPoTsyo does not use cheques and does not have a petty cash so all revenue and expenses are done through bank transfers.

New laboratory machine: We bought and imported a new HumaStar 200 biochemistry analyzer from Germany for our biochemistry analysis. It is a big investment, but it will save cost because it is fully automated. Our new laboratory machine HUMASTAR 200 is working well. We began to use it in the last week of May and it helps reduce workload on our staff.

Higher cost: We try to select only regular suppliers that can sell us goods and services based on VAT 10% invoices. We do not reclaim the Value Added Tax that we pay. As required by new laws, we have begun to pay National Social Security Fund premiums for accident and health for our employees and peer educators.

ការរៀបចំគណនី និងអនុគណនីវ៉ីង៖ ដើម្បីកាត់បន្ថយចំណាយនៃការងារប្រមូលចំណូល ក៏ដូចជាការងារគ្រប់គ្រងសាច់ប្រាក់ចំណូល យើងបានសហការជាមួយធនាគារឯកទេសវ៉ីង ដែលមានគណនី និងអនុគណនីតាមតម្រូវការរបស់យើង។ អង្គការ ម.ព.ជ បានចំណាយថវិកា ៦០ដុល្លារអាមេរិកក្នុងមួយខែសម្រាប់សេវាប្រតិបត្តិការ។

WING Business Account and sub accounts: To save money on cost of revenue collection and to facilitate monitoring of where our revenue is coming from, we plan to open a WING business account for USD 60 per month, with as many sub-accounts as we need.

សម្ភារសប្បុរសធម៌៖ យើងបានទទួលបានសម្ភារមួយចំនួនពីវេជ្ជបណ្ឌិត គី កាណារី នាខែសីហា រួមានតុ ទូឯកសារការិយាល័យ និងម៉ូតូHonda Dream សេរីឆ្នាំ២០០៧ចំនួន ២ គ្រឿង(មួយគ្រឿងខូចមិនអាចប្រើបាន) ដែលជាទ្រព្យសម្បត្តិរបស់អង្គការ Nyemo។

Donation of old office furniture from Nyemo Cambodia. Thanks to Dr Kanary, on Sunday 19th of August, we received a useful donation from used office furniture that still belonged to Nyemo. We hired a truck to transport it all to our office.

ខាងផ្នែកព័ត៌មានវិទ្យា៖ ក្រុមបច្ចេកទេសព័ត៌មានវិទ្យារបស់យើងបានធ្វើទំនើបកម្មកម្មវិធីWindow នៅលើបណ្តាញ Server និងរៀបចំកម្មវិធីតំឡើងសម្រាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់យើងដោយប្រើធនធានមនុស្សពីខាងក្រៅ សម្រាប់ការធ្វើបច្ចុប្បន្នភាពកម្មវិធី។ យើងក៏បានធ្វើទំនើបកម្មលើ គេហទំព័ររបស់អង្គការម.ព.ជផងដែរ ដែលអាចតំឡើងនៅលើទូរស័ព្ទដៃ និងមានប្រព័ន្ធសុវត្ថិភាពប្រសើរជាងមុនតាមរយៈអាសយដ្ឋាន https://។

IT: Our IT upgraded WINDOWS on our server and we outsourced an upgrade of our own software application for our Database. MoPoTsyo's website: Our website is improved (www.mopotsyo.org), can be seen on mobile phone now and it is security with extra "s" in address the https://

ការរួមចំណែករៀបចំប្រព័ន្ធថែទាំសម្រាប់ជំងឺរ៉ាំ How MoPoTsyo helps to build a chronic care system

តាមរយៈរដ្ឋលេខាធិការក្រសួងសុខាភិបាល ឯកឧត្តម អេង ហួត បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងថ្មី (MoU) នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ ដែលគ្រប់ដណ្តប់កម្មវិធី រយៈពេល៣ឆ្នាំបន្តទៀត។

Ministry of Health: MoH Secretary of State, H.E. Prof Eng Huot, has signed our new Memorandum of Agreement (called "MoU") on 30 January 2018. It covers a period of 3 years.

និយាមសម្រាប់ការថែទាំបឋម លើជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម ត្រូវបានលើកយកមកពិភាក្សាក្នុងសិក្ខាសាលាថ្នាក់ជាតិមួយ នៅខេត្តសៀមរាប។ អ្នកចូលរួមបានផ្តល់អនុសាសន៍ ទទួលស្គាល់តួនាទីមិត្តអប់រំមិត្តដូចក្រុមទ្រទ្រង់សុខភាពភូមិដែរ។ វាអាចផ្តល់ឱកាសឱ្យមិត្តអប់រំមិត្ត ទទួលបានប្រាក់លើកទឹកចិត្តពីរាជរដ្ឋាភិបាល។ និយាមជាតិថ្មីបាននិយាយច្រើនដង អំពីតួនាទីមិត្តអប់រំមិត្ត ត្រូវបានសម្រេចជាចុងក្រោយ ដោយក្រុមការងារTASK-FORCES របស់ក្រសួងសុខាភិបាល នាថ្ងៃទី២០ ខែធ្នូ។ អង្គការ ម.ព.ជ ក៏ជាសមាជិកនៃក្រុមការងារនេះផងដែរ។ ក្នុងនិយាមនេះ បាននិយាយអំពីតួនាទីរបស់មិត្តអប់រំមិត្ត ជាការងារស្ម័គ្រចិត្ត ដែលអាចជួយដល់ការងារផ្តល់សេវាថែទាំបឋមសម្រាប់ជំងឺ រ៉ាំ រ៉ែមិនឆ្លងនេះ។ វារំពឹងនឹងបោះពុម្ពផ្សាយនាដើមឆ្នាំ២០១៩។

The new *Primary Care Guideline for Diabetes and Hypertension* was discussed during an MoH Workshop Siem Reap. Participants issued recommendations that Peer Educators become "Village Health Support Group" (recognised by Ministry of Interior). This would qualify them for financial incentives from the government. The new guideline with a lot of references to the peer educators was finalized by official Ministry of Health working group on 20-12-2018 by the task force. MoPoTsyo is member. It describes the role of peer educators in this new guideline as volunteers who can help. Approval of the guideline by the Minister is expected for early 2019.

អង្គការម.ព.ជ និងមជ្ឈមណ្ឌល Center of Hope បានចុះកិច្ចព្រមព្រៀងលើការបណ្តុះបណ្តាល តាមបែបអនុវត្តជាក់ស្តែង លើការពិគ្រោះជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាមដល់ក្រុមវេជ្ជបណ្ឌិតមកពីមន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព ដែលបាននឹងកំពុងសហការជាមួយអង្គការម.ព.ជ។ វគ្គបណ្តុះបណ្តាលមានរយៈពេល ២សប្តាហ៍ និងមានចំនួន០២នាក់ក្នុងមួយវគ្គ។ វាបានចាប់ផ្តើមនៅខែសីហា ឆ្នាំ២០១៨។ ការសហការនេះ មានផលប្រយោជន៍ច្រើនដោយបានធ្វើឱ្យសិក្ខាកាមមានទំនុកចិត្តជាងមុន ក្នុងការផ្តល់សេវាពិគ្រោះដល់អ្នកជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាមនៅតាមមន្ទីរពេទ្យ/មណ្ឌលសុខភាពរបស់ពួកគេ។

សិក្ខាសាលាអំពីការទំនាក់ទំនងនៃជំងឺរបេងនិងជំងឺទឹកនោមផ្អែម៖ លោកប្រធានអង្គការម.ព.ជ បានធ្វើបទបង្ហាញអំពីកម្មវិធីបណ្តាញមិត្តអប់រំមិត្តនាថ្ងៃទី២៥ ខែធ្នូ ជាសិក្ខាសាលារៀបចំដោយអង្គការអភិវឌ្ឍសុខភាពនិងសង្គម HSD។ អង្គការ HSD ចង់បានការសហការរវាងមិត្តអប់រំមិត្តនៅក្នុងស្រុកប្រតិបត្តិដូនកែវ និងគីរីវង់នៃខេត្តតាកែវ ក្នុងការស្រាវជ្រាវរកករណីជំងឺរបេងក្នុងចំនោមអ្នកជំងឺទឹកនោមផ្អែម។

សិក្ខាសាលាបណ្តុះបណ្តាលវេជ្ជបណ្ឌិតមូលដ្ឋាន៖ យើងបានប្រើប្រាស់ថវិកាដែលនៅសល់ចុងឆ្នាំ២០១៨ ក្នុងការរៀបចំឱ្យមានសិក្ខាសាលាបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពវេជ្ជបណ្ឌិតមូលដ្ឋានក្នុងការពិគ្រោះជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម។ សិក្ខាសាលានេះមានរយៈពេល ២ថ្ងៃ ដោយបានអញ្ជើញវេជ្ជបណ្ឌិតជំនាញ និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ជាវាគ្មិនផងដែរ។

Center of Hope and MoPoTsyo signed a training contract: CoH train-on-the-job Medical Doctors in medical consultations for Diabetes and Hypertension. We chose government doctors from rural hospitals and selected Health Centers. Training is during 2 weeks in groups of 2. The trainings started in August 2018. After these trainings the doctors are more confident to do the medical consultations in their own referral hospital in districts where we have a peer educator network. Cooperation with Center of Hope is good.

TB & DM Workshop: I presented our program on 25 December 2018, organized by Cambodian NGO HSD. They want to work with our peer educators in Kirivong OD to link between the Diabetes and the TB program there.

2-Day Training of Doctors: With the funds left over at the end of 2018 from the revenue of consultations we organized a two-day-training of 30 doctors from rural hospitals and health centers, in Phnom Penh. Trainer was Dr Em Savoeun, Associate Professor at the Faculty of Medicine.

ដំណើរការសមាហរកម្ម INTEGRATION WITH THE PUBLIC HEALTH SYSTEM

បើមើលត្រលប់ទៅកាន់ឆ្នាំ២០០៥ ជាពេលដែលយើងបានបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្ត២នាក់ដំបូង សម្រាប់ការអនុវត្តកម្មវិធីបណ្តាញមិត្តអប់រំមិត្តតាមតំបន់ក្រីក្រក្នុងទីក្រុង នោះយើងអាចចង្អុលបង្ហាញឱ្យឃើញ អំពីចំនុចគោលដៅនៃដំណើរឆ្ពោះទៅរកសមាហរណកម្មកម្មវិធី ទៅក្នុងប្រព័ន្ធសុខាភិបាលសាធារណៈ។ ឆ្នាំ២០០៧ យើងបានបង្កើតបណ្តាញមិត្តអប់រំមិត្តនៅតាមជនបទជាលើកដំបូង តាមរយៈការបង្កើតមិត្តអប់រំមិត្តម្នាក់ សម្រាប់ទទួលខុសត្រូវក្នុងតំបន់មណ្ឌលសុខភាពមួយ ហើយក៏ជាលើកដំបូងដែរ ដែលយើងបានជួលវេជ្ជបណ្ឌិតជំនាញមួយរូបពីទីក្រុងភ្នំពេញ ដើម្បីផ្តល់សេវាពិគ្រោះជំងឺនៅមន្ទីរពេទ្យបង្អែក ដល់សមាជិកចំនួន៣០នាក់ក្នុងមួយព្រឹក។ ការពិគ្រោះជំងឺនោះ ធ្វើឡើងក្នុងអគារពិគ្រោះផ្នែកជំងឺក្រៅ(អគារអេដស៍)របស់មន្ទីរពេទ្យ។ បន្ទាប់មកនៅឆ្នាំ២០១០ សំណាកឈាម និងសំណាកទឹកនោមជាលើកដំបូងដែលប្រមូលពីសមាជិកទាំង៣០នាក់ខាងលើ ត្រូវបានផ្ញើមកមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៅភ្នំពេញ។ នៅឆ្នាំ២០១២ យើងបានដាក់ឱ្យដំណើរការ លក់ឱសថសម្រាប់សមាជិកនៅក្នុងមន្ទីរពេទ្យបង្អែករបស់រដ្ឋជាលើកដំបូង ដែលផ្តល់លទ្ធភាពឱ្យសមាជិកអាចទិញថ្នាំ (ឱសថបង្វិលទុននាំចូលដោយអង្គការ ម.ព.ជ) សម្រាប់ព្យាបាលជាប្រចាំរបស់ពួកគេដោយពុំចាំបាច់ត្រូវទៅជួបពិគ្រោះជំងឺសារឡើងវិញជាមួយគ្រូពេទ្យជំនាញទៀតទេ។ នៅក្នុងឆ្នាំ២០១៣ ក្រសួងសុខាភិបាលបានអនុម័តផែនការយុទ្ធសាស្ត្រ ដើម្បីការពារនិងគ្រប់គ្រងជំងឺមិនឆ្លងសំរាប់ឆ្នាំ២០១៣-២០២០។ ផែនការយុទ្ធសាស្ត្រ ត្រូវបានផ្សព្វផ្សាយទូលំទូលាយនាខែមេសា ឆ្នាំ២០១៤។

ផែនការយុទ្ធសាស្ត្រជាតិនេះ មានសារសំខាន់ណាស់ដោយសារថា ផ្អែម និងជំងឺលើសសម្ពាធឈាម ក្រសួងសុខាភិបាលបាននិយាយអំពីសកម្ម ភាពរបស់បណ្តាញមិត្តអប់រំមិត្តសម្រាប់ជំងឺទឹកនោមព្រមទាំងលើកឡើងឱ្យមានការពង្រីកបណ្តាញនេះ ឱ្យបានទូលំទូលាយទូទាំងប្រទេសទៀតផង។ ចាប់ពីពេលនោះមក បញ្ហាប្រឈមបានប្តូរចេញពី "ថាតើយើងត្រូវធ្វើសមាហរណកម្មកម្មវិធីទៅក្នុងប្រព័ន្ធសុខាភិបាលដែរឬទេ?" ទៅជា "តើយើងត្រូវធ្វើសមាហរណកម្មតាមរបៀបណា"។

Looking back to 2005, when we began to train the first two peer educators for their activities in poor urban areas, we can pinpoint to several milestones on the road to integration with the public service: In 2007: The first rural peer educator network of one peer educator per health center coverage area, and the first Phnom Penh Doctor hired to travel to a rural Referral Hospital do a medical consultation session seeing around 30 patients during a morning session. This consultation session took place at the MMM building (for HIV-AIDS). In 2010, the first blood-, serum and urine collections among a group of about 30 members at a Health Center and preparation for cool-transport to the central laboratory in Phnom Penh for the biochemistry lab profile. In 2012: The first public referral hospital pharmacy beginning to sell routine medication (imported through MoPoTsyo's Revolving Drug Fund) to patients who are network-members without requiring them to see their Doctor every time they just come for a refill of their prescription. In 2013, the MoH approved the National Strategic Plan for Prevention and Control of NCD 2013 – 2020, disseminated in 2014. This MoH plan is important because it explicitly mentions peer educator networks for diabetes and hypertension 28 times on 9 pages, and calls for their continuation and expansion. From then onwards, the challenge shifted from the question "if" the peer educator networks must be integrated" to "how" they must be integrated with the public health system.

ដូចគ្នា ទៅនឹងប្រព័ន្ធសុខាភិបាលរបស់ប្រទេសកំពុងអភិវឌ្ឍន៍នានាដែរ ស្ថាប័នម្ចាស់ជំនួយតែងផ្តោតជាសំខាន់ទៅលើការចាត់ចែងអង្គភាពរបស់ក្រសួងសុខាភិបាល និងប្រព័ន្ធសុខាភិបាលសាធារណៈ។ ប្រព័ន្ធសុខាភិបាលរបស់ប្រទេសកម្ពុជា ត្រូវបានរៀបចំ និងគ្រប់គ្រងតាមផ្នែក យោងទៅលើប្រភពហិរញ្ញប្បទាន ជាទូទៅគឺផ្តោតចំពោះតែបញ្ហាសុខភាពមួយចំនួន ជាជាងឆ្លើយតបនឹងតម្រូវការចាំបាច់។ ទោះបីបច្ចុប្បន្ន បញ្ហាជំងឺរ៉ាំរ៉ៃជាមូលហេតុធំ តំណាងឱ្យជាងពាក់កណ្តាលនៃអត្រាឈឺ និងអត្រាការស្លាប់ក៏ដោយ ប៉ុន្តែសេវាព្យាបាលអ្នកជំងឺរ៉ាំរ៉ៃ គឺនៅតែធ្វើដូចជាការព្យាបាលប្រភេទជំងឺស្រួចស្រាវទៅវិញ ឬអាចនិយាយបានសេវាព្យាបាលសម្រាប់តែការជួលជុលប៉ុណ្ណោះ គ្មានការថែទាំបន្តទេ។ ការឆ្លើយតបខាងតាមរយៈការរៀបចំ និងគ្រប់គ្រងដែលចាំបាច់សម្រាប់ការថែទាំអ្នកជំងឺរ៉ាំរ៉ៃនៅថ្នាក់ស្រុកប្រតិបត្តិ គឺ សម្រាប់បញ្ហារ៉ាំរ៉ៃច្រើនយ៉ាង ដែលមានលក្ខណគន្លឹះជាប្រព័ន្ធប្រហែលគ្នា ទោះបីជាជំងឺផ្សេងៗគ្នាក៏ដោយ។ លក្ខណៈចាំបាច់ពិសេសនៃថែទាំជំងឺរ៉ាំរ៉ៃ ត្រូវបានបង្ហាញ និងត្រូវពង្រឹងដូចខាងក្រោម៖

១. រៀបចំកូដអត្តសញ្ញាណកម្មអ្នកជំងឺម្នាក់ៗ សម្រាប់កត់ត្រារាល់ព័ត៌មានទាក់ទងនឹងសេវាជំងឺរ៉ាំរ៉ៃរបស់អ្នកជំងឺ ដែលនឹងផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រង និងវិភាគ ការព្យាបាលប្រកបដោយប្រសិទ្ធភាព ជាពិសេសការពិគ្រោះជំងឺ និងការផ្តល់ឱសថ។

២. បើកឱកាសឱ្យអ្នកជំងឺ និងសហគមន៍របស់គេ មានលទ្ធភាពគ្រប់គ្រងជំងឺដោយខ្លួនឯង ជាជាងការងារព្យាបាលតាមប្រពន្ធ័វិជ្ជាជីវៈ ដោយគ្រាន់តែផ្តល់ថ្នាំជាមូលដ្ឋានមួយចំនួនរបស់គ្រូពេទ្យតែប៉ុណ្ណោះ ។

៣. លុបបំបាត់ឧបសគ្គដែលមិនគួរកើតមួយចំនួនក្នុងការផ្តល់សេវា ដូចជា បញ្ហាអ្នកជំងឺត្រូវពិគ្រោះជំងឺ មុនពេលផ្តល់ឱសថម្តងៗ ហើយអនុញ្ញាតឱ្យអ្នកជំងឺប្រើវេជ្ជបញ្ជាចាស់ ដើម្បីទទួលសេវាឱសថ ក្នុងរយៈពេលសមស្របណាមួយ។

៤. ផ្តោតលើ ការបង្កើតឱ្យមានភ្ជាប់បណ្តាញទំនាក់ទំនងថែទាំបឋមនៅកន្លែងដែលត្រូវការ ជាមួយកម្មវិធីការងារសុខភាពសម្រាប់ជំងឺផ្សេងៗ ដូចជា រមេង និងអេដស៍ ជាដើម។

Like in many other developing countries' health systems, donor funding weighs heavily onto the organization of the MoH and the public health system. Cambodia's public health system has been organized partly according to the source of financing, often for specific health issues. Although chronic health problems represent now more than half of morbidity and mortality, health services still treat them as if they are acute disease episodes: only repair, no maintenance care. The organizational and managerial responses that are needed to provide chronic care inside the Operational Districts for multiple chronic problems have many key systemic features in common, even though the specific diseases can be very different. Key features of chronic care will have to be introduced or strengthened, such as:

1. Make that a unique Patient ID records all relevant chronic care data in such a way that they can be easily accessed for management and analysis of treatment effectiveness, including prescription and dispensing of medication;
2. Encouraging and enabling patients and communities of patients to self-manage instead of professionalising and medicalising simple services;
3. Abolishing unnecessary barriers to care, such as the requirement that patients must first personally see the doctor "every time they only need a refill of their prescription medication;
4. Focus on creating functional linkages at primary care level, where desirable, with other disease-programs, such as TB and HIV-AIDS.

៥. ធ្វើវិមជ្ឈការសេវាថែទាំ ដោយធ្វើឱ្យមានសេវាសុខភាពនៅជិតអ្នកជំងឺ។ បង្កើតតួនាទីបន្ថែមឱ្យមណ្ឌលសុខភាពនៅឆ្ងាយពីមន្ទីរពេទ្យបង្អែក សម្រាប់ផ្តល់សេវាថែទាំជំងឺរ៉ាំរ៉ៃ ដល់អ្នកជំងឺដែលរស់នៅជិតមណ្ឌលសុខភាព ជាជាងឱ្យអ្នកជំងឺទាំងនោះទៅកាន់មន្ទីរពេទ្យបង្អែកដែលនៅឆ្ងាយ។

៦. រៀបចំផែនការ សម្រាប់អ្នកធ្វើការខាងសុខភាពតាមសហគមន៍។ បង្កើតតួនាទីផ្លូវការច្បាស់លាស់ សម្រាប់អ្នកធ្វើការសុខភាពតាមសហគមន៍ ដូចជា បណ្តាញមិត្តអប់រំមិត្ត ដែលត្រូវគ្រប់គ្រងដោយការិយាល័យស្រុកប្រតិបត្តិ។ បង្កើតទំនាក់ទំនងជាក់លាក់រវាងមណ្ឌលសុខភាព និងបណ្តាញមិត្តអប់រំមិត្ត។

៧. ឯកភាព លើសុច្ចនាករសុខភាពមួយចំនួនសម្រាប់ជំងឺរ៉ាំរ៉ៃ នៅថ្នាក់ស្រុកប្រតិបត្តិ និងប្រព័ន្ធរបាយការណ៍លទ្ធផល ដែលផ្តល់លទ្ធភាពដល់ថ្នាក់ស្រុកប្រតិបត្តិធ្វើបច្ចុប្បន្នភាពទិន្នន័យយ៉ាងទៀតទាត់ នៅក្នុងតំបន់គ្របដណ្តប់មណ្ឌលសុខភាពនីមួយៗក្នុងស្រុកប្រតិបត្តិ។

៨. ដាក់បញ្ចូលនូវទិន្នន័យ និងសុច្ចនាករសំខាន់មួយចំនួនបង្ហាញអំពីលទ្ធផលនិងវិសាលភាពនៃប្រសិទ្ធភាពក្នុងការព្យាបាល សម្រាប់ក្រុមគោលដៅ។

៩. ផ្លាស់ប្តូរកញ្ចប់ថ្លៃសេវារួមមួយ សម្រាប់អ្នកជំងឺមួយ ទៅជាកញ្ចប់ថ្លៃសេវាផ្សេងៗ ជាមួយនិងតម្លៃផ្សេងៗគ្នាដែលអាចឆ្លើយតបបានល្អ ចំពោះតម្រូវការរបស់អ្នកជំងឺម្នាក់ៗ។ អ្នកជំងឺរ៉ាំរ៉ៃដែលមានការយល់ដឹងច្រើនអំពីសេវាថែទាំ យល់ថាអ្នកជំងឺរ៉ាំរ៉ៃ មិនត្រូវការកញ្ចប់សេវាតែមួយដូចគ្នារៀងរាល់ខែនោះទេ។

១០. រៀបចំវគ្គបណ្តុះបណ្តាលគ្រូពេទ្យ និងបុគ្គលិកសុខាភិបាល អំពីការរៀបចំថែទាំជំងឺរ៉ាំរ៉ៃ ក៏ដូចជាអំពីការភ្ជាប់ទំនាក់ទំនងជាមួយកម្មវិធីសុខភាពនានា និងការលើកទឹកចិត្តស្រុកប្រតិបត្តិណាដែលអនុវត្តន៍បានល្អ។

គោលនយោបាយផ្លូវការសុខាភិបាលសាធារណៈ បានបង្ហាក់ដល់ដំណើរការកែតម្រូវ និងអនុវត្តនូវលក្ខខណ្ឌចាំបាច់ទាំងនេះ។ អង្គការសុខភាពពិភពលោក បានដាក់ចេញនូវគោលនយោបាយកញ្ចប់សេវាថែទាំជំងឺមិនឆ្លង(Package of Essential Noncommunicable)ជាសកល សម្រាប់អនុវត្តជាការសាកល្បងនៅកម្ពុជាចំនួន ៣មណ្ឌលសុខភាព ប៉ុន្តែការអនុវត្តនេះ មិនមានការចូលរួមពីសហគមន៍ឡើយ ទោះបីជា

5. Decentralizing care, by bringing care closer to people: Creating a role for selected health centers, located far away from the referral hospital, for delivery of "maintenance chronic care" to patients who live closer to the health center than the referral hospital;

6. Framing lay-health worker activities: Officializing a clearly described lay-health worker role for specialized volunteers such as peer educators which can be supervised by the OD; formalize the relationship between the PE and the Health Center and assign 1 person in each Health Center with whom the PE works together.

7. Agreeing on a set of performance indicators of the chronic care system inside the OD and the related Dashboard so the OD authority has a regularly updated overview of the situation per health center area;

8. Including outcome data and indicators that reveal whether care is effective and to what extent it works for the target group

9. Change the 1 fixed care package for a 1 fixed user fee into a few different packages with a few different fees, which respond better to the individual patient needs. Every empowered chronic patient realizes that not everyone needs every month the same package.

10. Organize trainings of health authorities and health staff on the organization of maintenance care for chronic patients, as well the organization of the linkages with other disease programs, and reward best performing OD's;

Official health policy rules prevent many of these key features from being adopted or implemented. The WHO introduced its international PEN policy in Cambodia to inspire 3 HC pilots,

សហគមន៍គឺជាមូលដ្ឋានគ្រឹះរបស់វាក៏ដោយ។ ការអនុវត្ត សាកល្បង PEN របស់អង្គការសុខភាពពិភពលោក នៅតាមមណ្ឌលសុខភាពទាំង៣ មិនសូវខុសគ្នាពីសេវាព្យាបាលជំងឺស្រួចស្រាវ(acute care) ដែលមានក្នុងប្រព័ន្ធសុខាភិបាលស្រាប់នោះឡើយ។

ក្រោមកិច្ចសហការជាមួយក្រសួងសុខាភិបាល យើងបានដាក់ចេញនូវកម្មវិធីថែទាំជំងឺរ៉ាំរ៉ៃ ដោយផ្អែកលើកញ្ចប់សកម្មភាពពិសេសសម្រាប់ជំងឺមិនឆ្លង(WHO-PEN) នៅក្នុងមណ្ឌលសុខភាពចំនួន២ ដោយបានដាក់បញ្ចូលសកម្មភាពបណ្តាញមិត្តអប់រំមិត្ត និងសេវាឱសថបង្វិលទុន(Revolving Drug Fund)។ ក្នុងឆ្នាំ២០១៥ ក្រសួងសុខាភិបាលបានសម្រេចថា មណ្ឌលសុខភាពបានរៀបចំខាងលើនេះ នឹងត្រូវបណ្តុះបណ្តាល និងបំពាក់បរិក្ខារ ដើម្បីផ្តល់សេវាដល់អ្នកជំងឺលើសសម្ពាធឈាមផង និងអ្នកជំងឺទឹកនោមផ្អែមផង។ ដូចនេះ មណ្ឌលសុខភាពមានតួនាទីថែទាំអ្នកជំងឺរ៉ាំរ៉ៃមិនទាន់ធ្ងន់នៅនឹងកន្លែង មិនចាំតែធ្វើរោគវិនិច្ឆ័យហើយបញ្ជូនទៅមន្ទីរពេទ្យបង្អែកនោះឡើយ។ វាមានន័យថា ជាពេលវេលាត្រូវបង្កើតការផ្តល់សេវាសមស្របសម្រាប់ជំងឺរ៉ាំរ៉ៃ ឬការព្យាបាលបែបថែទាំ "Maintenance Care" នៅកម្រិតមណ្ឌលសុខភាពហើយ។

តាមរយៈពេលនៃការធ្វើជាទីប្រឹក្សា និងតាមរយៈអង្គសិក្ខាសាលាមួយចំនួន ក្រសួងសុខាភិបាល និងអង្គការ ម.ព.ជ បានសម្រេចរួមគ្នា លើកញ្ចប់ស្តង់ដាបទដ្ឋានបណ្តោះអាសន្ន សម្រាប់ថ្នាក់ស្រុកប្រតិបត្តិយកជាមូល ដ្ឋានសំរាប់ធ្វើកិច្ចសន្យា ការអភិបាលនិងការគ្រប់គ្រងមិត្តអប់រំមិត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ប៉ុន្តែវាមិនត្រូវបានប្រើប្រាស់ឡើយ។ កញ្ចប់នៃបទដ្ឋានបណ្តោះអាសន្ន នោះរួមមាន:

- ២០សុច្ចនាការនៃស្តង់ដារប្រតិបត្តិប្រព័ន្ធថែទាំសុខភាពអ្នកជំងឺរ៉ាំរ៉ៃជាមួយបណ្តាញមិត្តអប់រំមិត្តនៅថ្នាក់ស្រុកប្រតិបត្តិ
- តារាងបង្ហាញលទ្ធផលសង្ខេប(Dashboard)មួយដែលមានមួយទំព័រ សង្ខេបអំពីសុច្ចនាការការងារស្នូលក្នុងតំបន់គ្របដណ្តប់ របស់មណ្ឌលសុខភាពរបស់ស្រុកប្រតិបត្តិ។
- ឯកសារមគ្គុទេសន៍ (Supervision Guideline) ដែលសរសេរអំពីមូលដ្ឋានគ្រឹះសម្រាប់អភិបាល ប្រពន្ធ័គ្រប់គ្រងជំងឺរ៉ាំរ៉ៃ និងសកម្មភាពបណ្តាញមិត្តអប់រំមិត្តផងដែរ។
- ឯកសារមគ្គុទេសន៍បណ្តុះបណ្តាលមិត្តអប់រំមិត្ត ដែលរៀបរាប់អំពីសកម្មភាព និងតួនាទីរបស់មិត្តអប់រំមិត្ត។

but these are implemented without community involvement although that is a core feature of PEN. The WHO's PEN in those health centers was mostly adapted to the existing acute care system.

In cooperation with MoH we have introduced chronic care - based on WHO PEN - at 2 health centers, but with involvement from the patient community through the peer educator network, and with a revolving drug fund. In 2015, MoH decided that selected Health Centers - once trained and equipped - will also have to provide chronic care to hypertension patients and diabetes patients, so not only detect new patients and refer them to the NCD clinic at the Referral Hospital but maintenance care for chronic patients without complications. This means that it is time to create delivery of appropriate chronic care or "maintenance care" as it is sometimes called.

In the official contract for the first hand-over of the responsibility for the management of a peer educator network from MoPoTsyo to the Operational District provisional standards had been included but so far they are not being used as tools to manage the peer educator networks

- a set of 20 standard performance indicators of the chronic care system in the Operational District with a peer educator network.
- a Dashboard, that shows one 1 page an overview of the core indicators per Health Center area in the OD
- a Supervision Guideline which outlines the basics for supervising the chronic care system including the peer educator activities
- a Training Guideline for Peer Educators which contains what peer educators should know and what they should do.

នៅក្នុងកិច្ចសន្យាផ្លូវការអំពីការផ្ទេរកម្មវិធី និងការគ្រប់គ្រងបណ្តាញមិត្តអប់រំមិត្ត រវាងអង្គការម.ព.ជ និងស្រុកប្រតិបត្តិចំនួន២ ត្រូវបានធ្វើនាខែមីនា២០១៦ និងស្រុកប្រតិបត្តិចំនួនមួយទៀតនាខែឧសភា ២០១៨នេះ។ កិច្ចសន្យាអំពីការផ្ទេរ និងអ្វីដែលបានរៀបរាប់និងភ្ជាប់ជាមួយកិច្ចសន្យាគឺនៅតែមានសារសំខាន់។ ខ្លឹមសារសំខាន់ៗមួយចំនួនអំពីការថែទាំជំងឺរ៉ាំរ៉ៃ មិនមានចែងក្នុងគោលការណ៍ផ្លូវការរបស់ក្រសួងសុខាភិបាលនៅឡើយ។ ដូចនេះ ខ្លឹមសារសំខាន់ៗទាំងនោះត្រូវដាក់ ដូចជាក្រមប្រតិបត្តិសំរាប់ឲ្យអនុវត្តក្នុងចំណោមអ្នកពាក់ព័ន្ធនានាដូចជា ថ្នាក់ស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក ឱសថស្ថានដៃគូ មិត្តអប់រំមិត្ត និង មណ្ឌលសុខភាព ជាដើម។ ដូចនេះហើយ បានជាអ្នកពាក់ព័ន្ធទាំងនោះបានចងក្រងជាខ្លឹមសារណែនាំ ជាក្រមប្រតិបត្តិសម្រាប់ការងារ និងកិច្ចសហប្រតិបត្តិការរបស់ពួកគេ។

វានឹងក្លាយជាការចាប់អារម្មណ៍ ប្រសិនបើក្រសួងសុខាភិបាល អាចធ្វើការសិក្សាអំពីប្រសិទ្ធភាពការងារនៃការផ្ទេរកម្មវិធីនៅពេលដែលខ្លឹមសារ និងឯកសារក្រមប្រតិបត្តិការងារបណ្តាញមិត្តអប់រំមិត្តមួយចំនួន មិនត្រូវបានអនុវត្តដោយជំនួសនូវក្រមការងារថ្មី ដែលតម្រូវឱ្យស្របតាមប្រព័ន្ធសុខាភិបាលសាធារណៈដែលមានស្រាប់។

The hand-over of the first two networks took place in March 2016 and another network in May 2018. The contracts remain necessary because many of the key features of the chronic care system are not regulated by MoH policy so they have to be laid down as rules of engagement among local stakeholders, such as the OD, the Hospital, the contracted pharmacies, the peer educators, the health centers etc. so they have written rules to guide their work and their collaboration.

It will be interesting for MoH to study the effects of the hand-over because some key-features from the peer educator networks were abolished or replaced with other features in order to adapt to the existing public health system.

ការបន្ត និង ការពង្រីកបណ្តាញមិត្តអប់រំមិត្ត CONTINUATION & EXPANSION THE NETWORKS

បណ្តាញមិត្តអប់រំមិត្ត ត្រូវបានដំណើរការក្នុងលក្ខខណ្ឌអភិវឌ្ឍន៍កម្មវិធីផ្សេងៗគ្នា វាជាការឆ្លើយតបនូវផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធនឹងជំងឺមិនឆ្លងឆ្នាំ២០១៣ ដល់ឆ្នាំ ២០២០ ដែលយុទ្ធសាស្ត្រនេះ ត្រូវមានការបន្ត និងពង្រីកបណ្តាញមិត្តអប់រំមិត្តសម្រាប់ជំងឺទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាម។ បណ្តាញមិត្តអប់រំមិត្តដែលមានភាពរឹងមាំមាននៅក្រុងភ្នំពេញ ខេត្តតាកែវ នៅក្នុងស្រុកប្រតិបត្តិគងពិសី និងកំពង់ស្ពឺ(ខេត្តកំពង់ស្ពឺ) និងនៅស្រុកប្រតិបត្តិប្រតិបត្តិថ្មពួក (ខេត្តបន្ទាយមានជ័យ) ស្រុកប្រតិបត្តិបារាយណ៍-សន្ទុក និងស្ទោង(ខេត្តកំពង់ធំ)។ ចំនែកបណ្តាញមិត្តអប់រំមិត្តថ្មីៗ និងមិនទាន់រឹងមាំមាននៅស្រុកប្រតិបត្តិ អង្គរជ័យ(ខេត្តកំពត) ស្រុកប្រតិបត្តិ ចំការលើ(កំពង់ចាម) និងស្រុកប្រតិបត្តិ រមាសហ៊ីក និងជីភ្ជ (ខេត្តស្វាយរៀង)។ ចំនែកនៅស្រុកប្រតិបត្តិជីភ្ជ ជាតំបន់ដែលជាបណ្តាញថ្មីទើបបង្កើតឡើងនៅដើមឆ្នាំ ២០១៧។ យើងមិនបានពង្រីកកម្មវិធីទៅកាន់ស្រុកប្រតិបត្តិថ្មីទៀតឡើយនៅក្នុងឆ្នាំ ២០១៨។

To carry out the MoH Strategic Plan for Prevention and Control of NCD 2013-2020, which calls for continuation and expansion of Peer Eductor Networks for Diabetes and Hypertension, there are several Peer Educator Networks but in different stages of development. Mature networks exist in Phnom Penh, all over Takeo province, in Kong Pisey OD, Kampong Speu OD and Oudong OD (Kampong Speu province) in Thmar Pouk OD (Banteay Meanchey province), in Stoong OD and Baray Santuk OD (Kampong Thom province)..New networks were set up in Angkor Chey OD (Kompot province), in Chamkarleu OD (Kampong Cham province) and Romeas Hek OD and Chiphou OD in (Svay Rieng province) . Of all these networks only the network in Chiphou OD was started in 2017. We did not expand the PE network to the new operation district in 2018.

រូបភាពទី 3៖ ទីតាំងបណ្តាញមិត្តអប់រំមិត្តនៅកម្ពុជា ឆ្នាំ២០១៨ ***Locations of Peer Educator Networks in Cambodia in 2018***



បណ្តាញមិត្តអប់រំមិត្តនៅក្នុងក្រុងភ្នំពេញ ត្រូវបានគិតថា មាន១ស្រុកប្រតិបត្តិ ដោយសារការបំបែកស្រុកប្រតិបត្តិរបស់ប្រព័ន្ធគ្រប់គ្រងសុខាភិបាល នៅកំពុងស្ថិតក្នុងដំណាក់កាលរៀបចំនៅឡើយ។ នៅក្នុងឆ្នាំ២០១៨នេះ អង្គការម.ព.ជ បាននឹងកំពុងបន្តកំណើនរបស់ខ្លួនទាំងអ្នកទទួលផល និងការចំណាយ។ ជាបណ្តើរៗ បណ្តាញមិត្តអប់រំមិត្តអាចផ្តល់សេវាដល់អ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសសម្ពាធឈាមកាន់តែទូលាយជាងមុន ដល់មនុស្សពេញវ័យនៅកម្ពុជា។

The Peer Educator Network in Phnom Penh is counted for the moment as 1 OD as a new administrative division into OD's is underway. During 2018 MoPoTsyo continued its growth in terms of beneficiaries and also of expenditures, gradually covering a larger adult population with the services of the Peer Educator Networks.

ការចំណាយ និងផ្លែចំណាយ EXPENSES AND COSTS

ចាប់ពីឆ្នាំ២០១៦មក អង្គការម.ព.ជបានប្រើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ Modified Cash សម្រាប់ប្រព័ន្ធគណនេយ្យ ដោយផ្អែកលើក្រុមសវនកម្ម CAM Accounting & Taxation។ ក្រុមសវនកម្មបានពិនិត្យមើលយ៉ាងលំអិត លើដំណើរការហិរញ្ញវត្ថុរបស់អង្គការម.ព.ជ និងបានធ្វើសវនកម្មចប់សព្វគ្រប់ដល់ដំណាច់ឆ្នាំ២០១៨ ដោយមិនមានកំហុស។

ដូចបានបង្ហាញ យើងបានចំណាយលើចំណូលថវិកាដែលទទួលបានប្រមាណ ២១,៧២៤ ដុល្លារអាមេរិក។ បន្ទាប់នេះគឺ តារាងចំណូលចំណាយសរុបលំអិតរបស់អង្គការម.ព.ជ ក្នុងឆ្នាំ២០១៨។

From 2016 onward we have been using "modified cash" basis for accounting as agreed with the new auditor, CAM Accounting & Taxation, the Cambodian member of Kreston International, website https://kreston.com/ . The audit team looked in great detail at our organization and completed the audit of 2018 without problems.

As shown, in 2018 we spent USd 21,724 more than we had received in income. A more detailed breakdown of MoPoTsyo's total Profit & Loss accounts in 2018 A more detailed breakdown of MoPoTsyo's total Profit & Loss accounts in 2018.

	Jan - Dec 18
Income	
410100 · FUNDS FROM EXTERNAL DONORS	141,741.78
Total 410100 · FUNDS FROM EXTERNAL DONORS	141,741.78
420000 · FUND FROM MOPOTSYO AS DONOR	
420100 · Revolving Drug Fund	565,502.50
420200 · Laboratory Services	91,374.37
420300 · Medical Consultation	86,928.68
420400 · Sale of Consumable & Other	23,575.22
420500 · Interest from deposit	16,737.54
420600 · Gain/Loss from Exchange	-2,364.75
Total 420000 · FUND FROM MOPOTSYO AS DONOR	781,753.56
Total Income	923,495.34
Total Income	923,495.34
Expense	
500000 · PROJECT ACTIVITY COSTS	
510000 · CAPACITY OF PEER EDUCAT	15,297.33
520000 · EARLIER DIAGNOSIS &AWAREN	757.38
530000 · ORGAISING&DELIVER OFCARE	534,096.98
540000 · DISCOUNT VOUCHER	6,831.82
550000 · CAPACITY OF OD	99,420.84
560000 · ACTION RESEARCH PROJECTS	6,466.16
Total 500000 · PROJECT ACTIVITY COSTS	662,870.51
600000 · PROJET OPERATION COSTS	
612000 · Executive Management HQ	136,188.08
613000 · Operational Level(Filed)	401.14
614000 · Fringe Benefits	25,707.12
620000 · EQUIPMENT	41,996.60
630000 · OFFICE RUNING COSTS	43,245.80
640000 · OTHER COSTS	34,713.11
650000 · Bad debt expense	96.66
Total 600000 · PROJET OPERATION COSTS	282,348.51
Total Expense	945,219.02
Net Income	-21,723.68

របាយការណ៍ខាងក្រោមនេះ គឺជាការគណនានៃការចំណាយ និងថ្លៃដើមសេវានីមួយៗ។ តួរលេខនៃការចំណាយបង្ហាញថាសេដ្ឋកិច្ចមាត្រដ្ឋានបាន ធ្វើឲ្យការចំណាយសម្រាប់មនុស្សពេញវ័យម្នាក់ថយចុះ។ មនុស្សពេញវ័យម្នាក់ដែលបានគ្របដណ្តប់ ត្រូវបានកំណត់ជាមនុស្សម្នាក់ដែលធ្លាប់បានស្គាល់ជាមួយបណ្តាញតាមរយៈការចូលរួមរបស់គាត់ទៅក្នុងការធ្វើតេស្តស្ករក្នុងទឹកនោម និងរស់នៅក្នុងតំបន់ដែលបានគ្រប ដណ្តប់ដោយបណ្តាញមិត្តអប់រំមិត្តមួយ។ មនុស្សពេញវ័យដែលគ្របដណ្តប់ គឺជាអ្នកដែលសមាជិកភាពរបស់ពួកគេគឺអាចចុះឈ្មោះបាន ពេលណាគាត់កើតជំងឺទឹកនោមផ្អែម ហើយមិនចាំបាច់ជាសមាជិក ពីព្រោះអ្នកដែលទទួលបានផលប្រយោជន៍គឺ អ្នករាល់គ្នាដែលបានធ្វើស្រាវជ្រាវសម្រាប់ទឹកនោមផ្អែម។ ហេតុផលសម្រាប់ការប្រើប្រាស់នូវអត្ថន័យនេះ គឺផ្អែកលើទ្រឹស្តី រាល់មនុស្សពេញវ័យដែលទទួលស្រ្ទីប ទឹកនោមសម្រាប់ការធ្វើតេស្តទឹកនោមដោយខ្លួនឯង គឺបានដឹងថា មានបណ្តាញមិត្តអប់រំមិត្តរស់នៅក្នុងតំបន់របស់គាត់ដោយអាចជួបបានគ្រប់ពេលវេលា ដើម្បីធ្វើតេស្តម្តងទៀត ឬអាចផ្តល់ព័ត៌មាន។ បើល្អបំផុត តាមភូមិនីមួយៗគួរតែមានក្រុមលើសសម្ពាធឈាម ប៉ុន្តែជាក់ស្តែងក្រុមនេះមិនបានបង្កើតឡើយ។

អង្គការម.ព.ជ បានបង្កើតក្រុមលើសសម្ពាធឈាមតាមភូមិខ្លះៗរួចមកហើយ ប៉ុន្តែយើងមិនបានពង្រីកវាបន្ថែមឡើយ ពីព្រោះតែការចំណាយខ្ពស់ និងត្រូវមានយន្តការច្បាស់លាស់ក្នុងគាំទ្រ និងលើកទឹកចិត្តក្រុមបែបនេះ។

The following report presents calculations of both expenses and of costs per service unit. The expenses figures show that economies of scale make the expenses per covered adult go down. A covered adult is defined as a person who is familiar with the network through his/her participation in the diabetes raising awareness activites and who lives in an area covered by a peer educator network. A covered adult is someone for whom membership is open, so not necessarily yet a member, because the beneficiaries are everyone who has been screened for diabetes. The rationale for using this definition is as follows: Theoretically, every adult who has received a urine glucose strip for self-testing for diabetes, is aware that the peer educator is living in her/his area and available any time to do a blood glucose test or provide information. Ideally, there is High-Blood Pressure Group in this village, but in reality, it is not always been set up.

MoPoTsyo had set up some of this kind of HBPG in some villages but we did not expand this project becuase of high cost and procedure to support and motivate the groups is need to be revised.

តារាងទី ១៖ការចំណាយសម្រាប់អ្នកទទួលបានផលប្រយោជន៍ឆ្នាំ២០០៧_២០១៨ ***Expenses per Beneficiary 2007 – 2018***

Beneficiaries/expenses trend from 2007 to 2018 [in adults covered through the Peer Educator Networks in USD]												
Years / **End of month December**	**2007**	**2008**	**2009**	**2010**	**2011**	**2012**	**2013**	**2014**	**2015**	**2016**	**2017**	**2018**
Beneficiaries Annual growth %		143%	40%	57%	53%	91%	22%	27%	12%	18%	10%	0%
Beneficiaries												
Number of total population in OD's with PE	1,109,287	1,109,287	1,466,213	2,322,262	2,322,262	2806790	3,067,517	3,067,517	3,067,517	3,067,517	3,067,517	3,067,517
Number population at NCD risk (=adults)	632,294	632,294	835,741	1,323,689	1,323,689	1,599,870	1,748,485	1,748,485	1,748,485	1,748,485	1,748,485	1,748,485
Nr of covered&screened adults	**29,335**	**71,329**	**99,839**	**156,860**	**240,550**	**460,514**	**560,276**	**712,550**	**795,356**	**941,455**	**1,035,227**	**1,035,227**
Coverage of Total Population	2.6%	6.4%	6.8%	6.8%	10.4%	16.4%	18.3%	23.2%	25.9%	30.7%	33.7%	33.7%
Coverage of target population at risk	4.6%	11.3%	11.9%	11.9%	18.2%	28.8%	32.0%	40.8%	45.5%	53.8%	59.2%	59.2%
Total Expenses Annual growth %		120%	44%	37%	63%	23%	25%	-3%	-6%	28%	19%	4%
Total Annual Expenses [in USD]	$59,808	$131,725	$189,773	$260,446	$424,518	$521,013	$653,552	$635,385	$595,280	$763,952	$907,840	$945,220
Accumulated expenses of whole intervention		$191,533	$381,307	$641,752	$1,066,270	$1,587,283	$2,240,835	$2,876,220	$3,471,500	$4,235,452	$5,143,292	$6,088,512
Expenses per Unit per beneficiary [in USD]												
per population	$0.05	$0.12	$0.13	$0.11	$0.18	$0.19	$0.21	$0.21	$0.19	$0.25	$0.30	$0.31
per population at risk (all adults) of NCD	$0.09	$0.21	$0.23	$0.20	$0.32	$0.33	$0.37	$0.36	$0.34	$0.44	$0.52	$0.54
per covered & screened adult	**$2.04**	**$1.85**	**$1.90**	**$1.66**	**$1.76**	**$1.13**	**$1.17**	**$0.89**	**$0.75**	**$0.81**	**$0.88**	**$0.91**

ការចូលរួមអន្តរាគមន៍កាន់តែច្រើន គឺវាបានធ្វើឱ្យកាន់តែមានប្រសិទ្ធភាពជាមួយចំនួនដ៏ច្រើននៃអ្នកទទួលបានផលប្រយោជន៍ គឺទទួលបានសេវាជាមួយនឹងចំណាយទាបជាង។ ការចំណាយសម្រាប់មនុស្សពេញវ័យម្នាក់ ដែលធ្វើស្រាវជ្រាវត្រូវបានបំបែកជាអត្ថប្រយោជន៍ផ្សេងៗគ្នា ដែលមនុស្សពេញវ័យទាំងនេះអាចទទួលបាន អាស្រ័យទៅលើស្ថានភាពរៀងខ្លួនរបស់ពួកគេ ដូចបានឃើញនៅក្នុងតារាងខាងលើ។ ការផ្តល់នូវអត្ថប្រយោជន៍ គឺវាអាស្រ័យទៅលើតម្រូវការបុគ្គលម្នាក់ៗដោយតម្រូវការទាំងនេះមិនដូចគ្នាទេ។

With growth, the intervention is becoming more efficient, as larger numbers of beneficiaries are being served for less money. The expenses per screened adult have been broken down in different types of benefits that these adults can receive, depending on their individual situation, as can be seen in the table above. The provision of benefits depends on the needs of the individual as these needs are not the same for everyone.

បន្ទាប់ពីមានបណ្តាញមិត្តអប់រំមិត្ត និងបានធ្វើស្រាវជ្រាវក្នុងភូមិមួយហើយ ជាក់ស្តែងប្រជាជនដែលបានទទួលផលពីកម្មវិធី គឺជាចំនួនប្រជាជននៃភូមិទាំងមូល រួមទាំងកូនក្មេង មនុស្សពេញវ័យអ្នកទឹកនោមផ្អែមអ្នកអាចត្រៀមនឹងកើតជំងឺទឹកនោមផ្អែម និងអ្នកអាចត្រៀមនឹងកើតជំងឺលើសសម្ពាធឈាម។ ប្រព័ន្ធនៃបណ្តាញមិត្តអប់រំមិត្ត គឺរៀបចំទុកដើម្បីទទួលពួកគេ នៅពេលដែលពួកគេក្លាយទៅជាអ្នកទឹកនោមផ្អែម ឬអ្នកលើសសម្ពាធឈាម។

Once the peer educator network is established and has distributed urine strip in a village, in fact the entire village population is covered, whether they are a still a child, a healthy adult, a diabetic, pre-diabetic or pre-hypertensive. The system is ready to receive them when healthy adults become diabetic or hypertensive.

ប៉ុន្តែចាប់តាំងត្រីមាសទីបួន ឆ្នាំ២០១៤ មិត្តអប់រំមិត្ត បានចាប់ផ្តើមគិតប្រាក់ពីអ្នកជំងឺថ្មី ដែលចង់ចុះឈ្មោះជាសមាជិកនៃបណ្តាញនេះ ចំនួន២០,០០០រៀលសម្រាប់អ្នកជំងឺទឹកនោមផ្អែមម្នាក់ និង១៥,០០០រៀលសម្រាប់អ្នកជំងឺលើសសម្ពាធឈាមមិនមានទឹកនោមផ្អែម។

but from 4th quarter of 2014 PE started to charge new patients who want to register as member of the network, 20,000 Riel for a diabetic and 15,000 Riel to patients with hypertension without diabetes.

នាដំណាច់ឆ្នាំ ២០១៨ អង្គការ ម.ព.ជ បានចំនាយសរុបប្រមាណ ៦,០៨៨,៥១២ លានដុល្លាអាមេរិក គិតចាប់តាំងពីចាប់ដំណើរការកម្មវិធីក្នុងឆ្នាំ២០០៥ មក។

By the end of 2018, we have spent over six million USD dollars since we began operations in 2005

កំណើនសមាជិក ក្នុងបណ្តាញមិត្តអប់រំមិត្ត MEMBERSHIP GROWTH

រៀងរាល់ឆ្នាំ អង្គការម.ព.ជ បាននឹងកំពុងបង្រៀនមិត្តអប់រំមិត្តថ្មី បង្កើនកំលាំងការងារផ្នែកសុខាភិបាលនៅកម្ពុជា ដោយដាក់បន្ថែមកំលាំងពលកម្មដែលបានទទួលការបង្រៀនពិសេសមួយ ជួយឲ្យពួកគេអនុវត្តបានជាក់ស្តែង។ នេះជាធនធានមានសមត្ថភាពខ្ពស់ និងចំណាយថវិកាតិច សម្រាប់កិច្ចការសុខភាពសាធារណៈ។ ក្នុងឆ្នាំ២០១៨ មិត្តអប់រំមិត្តថ្មីចំនួន១៣នាក់ ត្រូវបានដាក់បញ្ចូលទៅក្នុងបណ្តាញមិត្តអប់រំមិត្ត។ នេះបង្ហាញនូវកំនើនប្រចាំឆ្នាំនៅក្នុងបណ្តាញមិត្តអប់រំមិត្តចាប់តាំងពីប្រតិបត្តិការចាប់ផ្តើម។ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៨ យើងមានមិត្តអប់រំមិត្តសរុប ២៤១នាក់ ដែលបណ្តុះបណ្តាលដោយអង្គការម.ព.ជ។ ក្នុងចំនោមពួកគេទាំងអស់នេះ មាន១៨២នាក់នៅតែបន្តធ្វើការជាមិត្តអប់រំមិត្ត។

Every year MoPoTsyo is training new Peer Educators (PE) increasing Cambodia's health workforce with lay workers having a received special training that makes them in practice. This is a highly effective and low cost resource for public health duties. In 2018, 13 new PE's were added to MoPoTsyo's network, representing yearly increase in PE's since operations began. From 2005 to 2018 there were a total of 241 PE's trained by MoPoTsyo. Among them 182 are still working as PE.

.

រូបភាពទី 4៖ ការកើនឡើងសមាជិកភាព Growing membership



ក្រាហ្វខ្សែនីមួយៗ តំណាងឱ្យចំនួនសរុបបូកបន្តនៃសមាជិកជាអ្នកជំងឺរ៉ាំរ៉ៃ ដែលទទួលផលប្រយោជន៍ពីបណ្តាញមិត្តអប់រំមិត្តចាប់តាំងពីឆ្នាំ២០០៥។ បើពួកយើងចង់ដឹងមានអ្នកជំងឺប៉ុន្មាននាក់ដែលបាកំពុងទទួលផលប្រយោជន៍ពីសេវាមិត្តអប់រំមិត្តក្នុងឆ្នាំ២០១៨ យើងត្រូវដកអ្នកគ្រប់គ្នាដែលយើងបានដឹងជាអ្នកជំងឺដែលបានស្លាប់និងអ្នកជំងឺដែលមិនប្រើប្រាស់សេវា អំឡុងឆ្នាំ២០១៨។

The lines represent the accumulation of chronic patients who have benefited from the Peer Educator Networks since 2005. If we want to know how many individual patients were actually benefiting during the year 2018, we have to deduct everybody of whom we know that they have died and who did not use the peer educator networks during the year 2018

លទ្ធផលគឺ ១៨,២៧៦នាក់នៃអ្នកជំងឺបានចុះឈ្មោះ កំពុងប្រើប្រាស់សេវាយ៉ាងសកម្ម (ច្រើនជាងឆ្នាំ២០១៧ ចំនួន ១,១៨៨ នាក់)។ ក្នុងចំនោមពួកគេ គឺមានអ្នកជំងឺទឹកនោមផ្អែមចំនួន ១៤,៦៣១នាក់ និងអ្នកជំងឺលើសសម្ពាធឈាមចំនួន ៣,៦៤៥ នាក់។ តួរលេខទាំងនេះ ត្រូវបានគណនាជាស្វ័យប្រវត្តិដោយប្រព័ន្ធទិន្នន័យដែលប្រមូលកំណត់ត្រានៃការប្រើប្រាស់សេវារបស់អ្នកជំងឺម្នាក់ៗ ប៉ុន្តែ វាផ្អែកលើទិន្នន័យ ដែលត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យ។

The result is that 18,276 (1,188 members more than in 2017) registered patients were actively using the services. Among them there were 14,631 DM and 3,645 HBP. These figures are automatically calculated by the database, which collects the records of the individual patient service use, but of course only if the data are entered into the database.

ជាក់ស្តែង ភាពខ្សោយនៃរបាយការណ៍បានធ្វើឱ្យតួរលេខនៃសមាជិកសកម្ម(អ្នកកំពុងប្រើសេវា) អាចខ្ពស់ជាង។ វានៅតែជាតួរលេខប៉ាន់ស្មាន។ នៅពេលអនាគត ពួកយើងមានគម្រោងផ្លាស់ប្តូរការប្រមូលទិន្នន័យពីសន្លឹកទម្រង់ដោយក្រដាស ទៅទម្រង់អេឡិចត្រូនិចនៅលើថាប្លេត(Tablet) ដែលមានស៊ីមដែលអាចទាញយកទិន្នន័យ ដោយស្វ័យប្រវត្តិទៅក្នុងប្រព័ន្ធទិន្នន័យតាមអ៊ីនធើណេត។ យើងសង្ឃឹមថា វាជួយឱ្យប្រព័ន្ធរបាយការណ៍របស់យើងកាន់តែត្រឹមត្រូវជាង។

We know that recording does not always happen so the figures of active patients can be an underestimate of actual number of active patients. In the future, we plan to move data collection from paper forms to electronic forms on tablets which can be synchronised with the database through the Internet.

យើងអាចប៉ាន់ប្រមាណអត្រាស្លាប់ពី ២%ទៅ ៣%ក្នុងមួយឆ្នាំ។ ប៉ុន្តែភាគច្រើនករណីស្លាប់ មិនត្រូវបានរាយការណ៍ ហើយកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យឡើយ។ ក្នុងតារាងខាងក្រោម(ផ្អែកលើមូលដ្ឋានទិន្នន័យ) បានបង្ហាញថាអត្រាអ្នកស្លាប់ក្នុងចំនោមសមាជិកដែលបានចុះឈ្មោះហើយ មានត្រឹមតែ ១.៣% ដែលក្នុងនោះ ភាគច្រើនជាសមាជិកអ្នកជំងឺទឹកនោមផ្អែម។ ចំនួនសមាជិកបោះបង់ បានកើនឡើងក្នុងឆ្នាំ ២០១៧ គឺជាបញ្ហាប្រឈមថ្មី ដែលត្រូវតែដោះស្រាយ។

We estimate a mortality rate of 2 to 3% yearly, but most cases remain unreported. In table below (part of database) shows that mortality rate among registered members is lower, in there mostly is diabetes members. The problem is the higher losses of patients in 2017. This has to be addressed more effectively.

យើងអាចប៉ាន់ប្រមាណអត្រាស្លាប់ពី ២%ទៅ៣% ក្នុងមួយឆ្នាំ ប៉ុន្តែភាគច្រើនករណីស្លាប់មិនត្រូវបានរាយការណ៍ ហើយកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យឡើយ។ ក្នុងតារាងខាងក្រោម(ផ្អែកលើមូលដ្ឋានទិន្នន័យ) បានបង្ហាញថាអត្រាអ្នកស្លាប់ ក្នុងចំនោមសមាជិកដែលបានចុះឈ្មោះមានត្រឹមតែ ០.៩១% ដែលក្នុងនោះភាគច្រើនជាសមាជិកអ្នកជំងឺទឹកនោមផ្អែម។ ចំនួនសមាជិកបោះបង់ បានកើនឡើងក្នុងឆ្នាំ ២០១៨ គឺជាបញ្ហាប្រឈមថ្មី ដែលត្រូវតែដោះស្រាយ។ ប៉ុន្តែ វាក៏លទ្ធផល ដែលមនុស្សមួយចំនួនត្រូវបានរកឃើញថាបានចុះឈ្មោះស្ទួន ហើយមិនបានលុបចេញពីប្រព័ន្ធទិន្នន័យ។

We estimate a mortality rate of 2 to 3% yearly, but most cases remain unreported. In table above (part of database) shows that mortality rate among registered members is lower, in there mostly is diabetes members. The problem is the higher losses of patients in 2018. This has to be addressed more effectively. It also indicates that the double registered and we did not remove the recordings from the database

តារាងទី 2៖ ការបាត់បង់ និងមរណៈភាព Lost and death

Beneficiaries During 2017		Since 2005				
	Active	Died	Lost	Total registered	Recorded deaths among registered	Patient Lost among registered
Diabetics	13,216	253	7,959	21,338	1.19%	37%
High Blood Pressure	3,872	54	8,073	11,974	0.45%	67%
Total	**17,088**	**307**	**16,032**	**33,312**	**0.92%**	**48.13%**

Beneficiaries During 2018		Since 2005				
	Active	Died	Lost	Total registered	Recorded deaths among registered	Patient Lost among registered
Diabetics	14,631	288	10,948	25,867	1.11%	42%
High Blood Pressure	3,645	63	9,060	12,768	0.49%	71%
Total	**18,276**	**351**	**20,008**	**38,635**	**0.91%**	**51.8%**

សកម្មភាពមិត្តអប់រំមិត្តរបស់អង្គការម.ព.ជ បានចាប់ផ្តើមក្នុងតំបន់ក្រីក្រតាមទីក្រុង នៅពាក់កណ្តាលឆ្នាំ២០០៥។ សកម្មភាពដំបូងរួមមាន សកម្មភាពចែកតេស្តជាតិស្ករក្នុងទឹកនោម និងការថែទាំសម្រាប់អ្នកជំងឺលើសសម្ពាធឈាមដែរ។ នៅពាក់កណ្តាលឆ្នាំ២០០៧ កម្មវិធីនេះត្រូវបានអនុវត្តដល់តំបន់ជនបទ នៅពេលមិត្តអប់រំមិត្តចាប់ផ្តើមទទួលការបង្រៀននៅស្រុកប្រតិបត្តិអង្គរកាខេត្តតាកែវ ជាមួយនឹងការឧបត្ថម្ភតិចតួច ពីអង្គការមូលនិធិទឹកនោមផ្អែមពិភពលោក កាកបាទក្រហមប្រទេសស្វីស MSFប្រទេសបែលហ្ស៊ិក និងអ្នកដទៃទៀត ដើម្បីអនុវត្តកម្មវិធីទូទាំងស្រុកប្រតិបត្តិអង្គរកាទាំងមូល។ កម្មវិធីបានបណ្តុះបណ្តាលមិត្តអប់រំមិត្តម្នាក់សម្រាប់មណ្ឌលសុខភាពមួយ។ គម្រោងនេះ គឺត្រូវបានបង្កើតឡើងតាមផែនការគ្រប់ដណ្តប់សុខភាព ថ្នាក់ជាតិដែលចំនួនប្រជាជននៅតាមទីតាំង មិនមែនតាមផ្នែករដ្ឋបាលថ្នាក់ខេត្តទៅរដ្ឋបាលថ្នាក់ឃុំ និងស្រុកឡើយ។ តាំងពីឆ្នាំ២០០៨ មិនមានការស្រាវជ្រាវទឹកនោមផ្អែមសកម្ម នៅតំបន់ទីក្រុងឡើយ។ មិត្តអប់រំមិត្តនៅទីក្រុងមានតែ៥នាក់ប៉ុណ្ណោះ បាននឹងកំពុងមមាញឹកតាមដានចំនួនអ្នកជំងឺទឹកនោមផ្អែមដ៏ច្រើនប្រៀបធៀបនឹងមិត្តអប់រំមិត្តជនបទច្រើនជាង ១៥០នាក់ផ្សេងទៀត បាននឹងកំពុងនៅធ្វើសកម្មភាពហើយ (អ្នកឆ្លងវគ្គបណ្តុះបណ្តាលមិត្តអប់រំមិត្តមានចំនួន១៨៨នាក់)។ មិនមានកម្មវិធីលើសសម្ពាធឈាមសកម្មក្នុងតំបន់ទីក្រុងឡើយ គឺមានតែនៅតំបន់ជនបទ។

MoPoTsyo Peer Education began in urban slums in mid 2005 with awareness raising for patients with diabetes (DM), including also care for diabetes patients with High Blood Pressure. In mid 2007 this intervention was piloted in a rural area, when peer educators began to be trained in Ang Roka OD in Takeo province with small amounts of funding from the World Diabetes Foundation, Swiss Red Cross, MSF Belgium and others to cover one entire operational district, with one peer educator per health center coverage area. The design was created to follow Cambodia's National Health Coverage plan which is population based and which does not follow the country's administrative division into communes and administrative districts. Since 2008, there is no more active diabetes screening in urban areas. The 5 urban peer educators are very busy following up large numbers of diabetic patients, compared to more than 150 active rural peer educators and (who passed PE training are 188). There is no active High Blood Pressure program in the urban area, only in rural areas.

កម្មវិធីក្រុមលើសសម្ពាធឈាមតាមភូមិ៖ ក្រុមតូចដំបូងមួយនៃសមាជិកលើសសម្ពាធឈាមគ្មានទឹកនោមផ្អែម ត្រូវបានជ្រើសរើសចូលកម្មវិធីនៅឆ្នាំ២០០៧។ តំបន់ក្រីក្រទីក្រុងយើងបានបង្កើតក្រុមលើសសម្ពាធឈាម ចំនួន៤ភូមិ។ បន្ទាប់ពីការខិតខំប្រឹងប្រែង២ដង យើងនៅតែមិនអាចរកមេក្រុម ឬសមាជិកក្រុមបានឡើយ។ បន្ទាប់មកវាត្រូវបានសាកល្បងក្នុងជនបទមានចំនួន ៦៣៤ក្រុម វាមិនស្ងួរដំណើរការល្អផងដែរ។ មានក្រុមតិចតួចប៉ុណ្ណោះ មានដំណើរការល្អ។

ពួកយើងបានបន្ថែម យុទ្ធនាការបង្ការបឋមអំពីជំងឺរ៉ាំរ៉ៃ សម្រាប់អាជ្ញាធរមូលដ្ឋាន និងសាលារៀនដល់គ្រូបង្រៀន។ យុទ្ធនាការនេះ បានធានាការគាំទ្របានយ៉ាងច្រើន សម្រាប់ការអន្តរាគមន៍ ប៉ុន្តែវាមិនអាចអនុវត្តបាននៅមជ្ឈដ្ឋានទីក្រុងដែលសំបូរដោយអ្នកចេះដឹង ព្រោះមិត្តអប់រំមិត្តមកពីតំបន់ក្រីក្រមានចំណេះដឹងទាប។ តាមតំបន់ជនបទ យុទ្ធនាការនេះត្រូវបានរកឃើញថា វាមានលទ្ធផលប្រសើរជាង។ ការសហការរវាងកម្មវិធីមិត្តអប់រំមិត្ត និងមណ្ឌលសុខភាព អំពីគម្រោងការអន្តរាគមន៍ជំងឺលើសម្ពាធឈាម មិនទាន់ល្អឡើយ។ កិច្ចការដែលត្រូវប្រឈម គឺមិនមែនត្រឹមតែរកឲ្យឃើញ និងផ្តល់សេវាពិគ្រោះជំងឺដល់សមាជិកលើសម្ពាធឈាមឡើយ ប៉ុន្តែគឺធ្វើយ៉ាងណា ដើម្បីឲ្យពួកគេទទួលបានវេជ្ជបញ្ជាត្រឹមត្រូវ ហើយពួកគេបន្តអនុវត្តការព្យាបាល ទោះបីគ្មានរោគសញ្ញា។

High Blood Pressure: An initial small group of members with High Blood Pressure, without diabetes, were recruited to the program in 2007 in urban slums. We created a Village High Blood Pressure group in 4 villages. After 2 attempts it did not catch on with the VHBGroup Leader nor the patients. Then it was tried in rural area with 634 groups, which initially also did not work well.

There we added a primary prevention campaign for community leaders and for school teachers. This latter feature helped to ensure wider support for the intervention, but it cannot be implemented in the high-class urban environment by low-educated slum-resident-peer educators. In the rural areas a provisional modus operandi was found which shows better results. The High Blood Pressure intervention design remains unfinished without proper links with the health centers. The challenge is not to detect and register and counsel members on High Blood Pressure but to make them get a prescription and especially to make them adhere to treatment once the symptoms are over.

រូបភាពទី 5៖ កំនើនប្រចាំឆ្នាំនៃសមាជិកភាព Yearly growth in membership



កំនើនប្រចាំឆ្នាំនៃអ្នកជំងឺទឹកនោមផ្អែម គឺបន្តិចម្តងៗ ច្រើនជាងអ្នកជំងឺលើសសម្ពាធឈាម។ គម្រោងអន្តរាគមន៍លើបញ្ហាលើសសម្ពាធឈាម នៅតែទាមទារការធ្វើការច្រើន និងសហប្រតិបត្តិការជិតស្និតជាមួយសេវាសាធារណៈ។

Yearly growth of active people with DM is more gradual than the active members with High BP. High BP intervention design still requires more work and closer collaboration with the public service to enhance its effectiveness.

មិត្តអប់រំមិត្តជាធនធានសុខាភិបាល PEER EDUCATORS AS HEALTH RESOURCES

ជារៀលរាល់ឆ្នាំ អង្គការម.ព.ជ បាននឹងកំពុងបង្រៀនមិត្តអប់រំមិត្តថ្មី បង្កើនកំលាំងការងារសុខាភិបាលនៅកម្ពុជា ដោយដាក់បន្ថែមកំលាំងពលកម្ម ដែលទទួលការបង្រៀនពិសេសមួយ ជួយឲ្យពួកគេអនុវត្តបានជាក់ស្តែង។ នេះជាធនធានមានសមត្ថភាពខ្ពស់ និងចំណាយថវិកាតិចសម្រាប់កិច្ចការសុខភាពសាធារណៈ។ ក្នុងឆ្នាំ២០១៨ មិត្តអប់រំមិត្តថ្មីចំនួន១៣នាក់ ត្រូវបានដាក់បញ្ចូលទៅក្នុងបណ្តាញអង្គការ ម.ព.ជ។ នេះបង្ហាញនូវកំនើនប្រចាំឆ្នាំ នៅក្នុងបណ្តាញមិត្តអប់រំមិត្តចាប់តាំងពីប្រតិបត្តិការចាប់ផ្តើម។ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០១៨ យើងមានមិត្តអប់រំមិត្តសរុប២៤១នាក់ ដែលបណ្តុះបណ្តាលដោយអង្គការម.ព.ជ។ ក្នុងចំនោមពួកគេទាំងអស់នេះ មាន១៨២នាក់នៅតែបន្តធ្វើការជាមិត្តអប់រំមិត្ត។

Every year MoPoTsyo is training new Peer Educators (PE) increasing Cambodia's health workforce with lay workers having a received special training that makes them in practice. This is a highly effective and low cost resource for public health duties. In 2018, 13 new PE's were added to MoPoTsyo's network, representing yearly increase in PE's since operations began. From 2005 to 2018 there were a total of 241 PE's trained by MoPoTsyo. Among them 182 are still working as PE.

រូបភាពទី ៦៖ ចំនួនមិត្តអប់រំមិត្តបានបណ្តុះបណ្តាល និង មិត្តអប់រំមិត្តនៅធ្វើការ Total numbers of PE trained and Active PE's



នៅចុងឆ្នាំ២០១៨ ភាគរយនៃមិត្តអប់រំមិត្តដែលនៅធ្វើការជាមួយអង្គការម.ព.ជនៅតែខ្ពស់៧៦% (១៨២នាក់នៃចំនួន២៤១នាក់)។ ទោះបីជាមានសញ្ញាតិចតួចនៃការធ្លាក់ចុះរហូតមកដល់ពេលនេះ ជាមួយការកើនឡើងនៃអាយុរបស់គេ នេះអាចនឹងទៅជាកត្តាមួយសម្រាប់ពេលអនាគត។

At the end of 2018, the percentage of PE's still working with MoPoTsyo remains high: 76% (182 out of 241). Although there is little sign of attrition until now, with climbing of their age, this must be factored in for the future.

រូបភាពទី 7៖ ចំនួនមិត្តអប់រំមិត្តដែលបានបណ្តុះបណ្តាលប្រចាំឆ្នាំ ***Yearly number of PE trained***



រូបភាពទី8៖ ភាគរយនៃមិត្តអប់រំមិត្តបន្តនៅជាមួយអង្គការ ម.ព.ជ ***Percentage of PE still with Mopotsyo***



ក្នុងឆ្នាំ២០១៥ ពួកយើងបានធ្វើការបង្រៀនសារជាថ្មីឱ្យមិត្តអប់រំមិត្តនូវបញ្ហាៗដូចជា ជំងឺទឹកដក់បាតភ្នែក បញ្ហាសុខភាពប្រអប់ជើង បញ្ហាលើសសម្ពាធឈាម និងជំងឺដាច់សរសៃឈាមក្នុងក្បាល ដោយសម្ភារសិក្សាមានលក្ខណៈពិសេសនៅក្នុងទម្រង់ជាវីដេអូគំនូរជីវចល។ ដូចគ្នាផងដែរ មិត្តអប់រំមិត្តបានទទួលការបង្រៀនពិសេស អំពីរបៀបពន្យល់ពីលទ្ធផលជីវគីមីសាស្ត្ររបស់មន្ទីរពិសោធន៍ទៅអ្នកជំងឺ។

ប្រសិនបើពួកយើងមើលលើហេតុផល ថាតើហេតុអ្វីពួកយើងបាត់បង់មិត្តអប់រំមិត្ត រូបភាពខាងក្រោមចាប់ផ្តើមលេចឡើង។ យើងឃើញថា មានមូលហេតុសំខាន់២ គឺ បោះបង់ និងស្លាប់។ ជាក់ស្តែងក្នុងឆ្នាំ២០១៨ មានមិត្តអប់រំមិត្ត បោះបង់ចំនួន ០នាក់ និងស្លាប់ចំនួន ២នាក់។

In 2015 we did refresher training the peer educators in issues such as Diabetic Retinopathy foot-wound and High Blood Pressure and Stroke by special educational materials in the form of an animated video. Also the peer educators have received special training in how to explain the biochemistry laboratory results to the patients.

If we look at the reasons why we lose a PE, the following picture begins to emerge (figure 8). We saw 2 main reasons were resignation and dead. In 2018, there were 0 PE who resigned and 2 died.

រូបភាពទី១៖ ហេតុផលសម្រាប់ការបាត់បង់មិត្តអប់រំមិត្ត ***Reasons for losing PE.***



ទន្ទឹមនឹងមានមិត្តអប់រំមិត្តភាគច្រើន ដែលបានទទួលការបណ្តុះបណ្តាល នៅបន្តធ្វើការជាមិត្តអប់រំមិត្តដដែល ក៏មានមិត្តអប់រំមិត្តមួយចំនួនតូច បានផ្លាស់ប្តូរមុខនាទីរបស់ពួកគេ ពីមិត្តអប់រំមិត្តស្ម័គ្រចិត្ត ទៅជាបុគ្គលិកទទួលប្រាក់ខែពីអង្គការ ម.ព.ជ។ នៅពេលពួកគេក្លាយទៅបុគ្គលិកទទួលប្រាក់ខែ មិត្តអប់រំមិត្តថ្មីត្រូវបានបណ្តុះបណ្តាលបន្ថែម ដើម្បីជំនួសមិត្តអប់រំមិត្តចាស់ ហើយត្រូវបន្តរស់នៅ និងស័ក្តិចិត្តក្នុងសហគមន៍។ ការផ្លាស់ប្តូរនេះ បានកើតឡើងច្រើនដងមកហើយ ជាពិសេសនៅក្នុងតំបន់ក្រីក្រទីក្រុង កន្លែងដែលអ្នកជំងឺជាច្រើនផ្លាស់តួនាទីពួកគេ ទៅជាបុគ្គលិកទទួលប្រាក់ខែរបស់អង្គការ ម.ព.ជ ជំនួសដោយអ្នកជំងឺចាស់របស់ពួកគាត់។ រហូតមកដល់ចុងឆ្នាំ២០១៨ ការិយាល័យអង្គការ ម.ព.ជ មានអតីតមិត្តអប់រំមិត្តចំនួន ៤នាក់ ធ្វើការជាបុគ្គលិកមានប្រាក់ខែ។

ពួកគាត់បានចូលរួមក្នុងការគ្រប់គ្រង ដំណើរការត្រួតពិនិត្យ និងចាត់ចែងកិច្ចការនៅក្នុងផ្នែកអនុវត្តកម្មវិធីគ្រប់គ្រងបណ្តាញមិត្តអប់រំមិត្តរបស់អង្គការ ម.ព.ជ។ ពួកគេជួយពង្រឹងសមត្ថភាពរបស់បណ្តាញមិត្តអប់រំមិត្តនៅស្រុកប្រតិបត្តិ។ នៅក្នុងភូមិសាស្ត្រ គ្របដណ្តប់ដោយមណ្ឌលសុខភាពនីមួយៗ ដែលគ្រប់ដណ្តប់ភូមិច្រើន និងមានចំនួនប្រជាជនរស់នៅចន្លោះពី ៨,០០០នាក់ ទៅចំនួន១៥,០០០នាក់ គឺមានមិត្តអប់រំមិត្តម្នាក់។

Many trained PE remain in role as PE over time, some change their status from being a volunteer Peer Educator to a salaried staff member. When they become salaried staff members, a new PE must be trained so he/she can replace the “ex”-PE who continues to live inside the community. This has happened several times, in particular in the urban slums, where several patients worked themselves into MoPoTsyo’s salaried positions , being replaced by their former patients. Until the end of 2018 MoPoTsyo HQ has 4 former Peer Educators working as salaried staff.

They are involved in management, supervision and have organisational tasks in the Capacity Building Dpt of MoPoTsyo where the Peer Educator Networks are being managed. They help strengthen the capacity of the Peer Educator Network at the OD level. There is only one PE for all villages covered by each health ceter area with numbers of residents between 8,000 to 15,000 people.

តារាងទី 3៖ មិត្តអប់រំមិត្ត និង អ្នកគ្រប់គ្រងមានប្រាក់ខែ PE & salaried supervisors

នៅចុងឆ្នាំ២០១៨ At the end of the year 2018			
ខេត្ত/ក្រុង Provinces/Municipalities	មណ្ឌលសុខភាពមានមិត្តអប់រំមិត្ត HC areas with PE	អ្នកគ្រប់គ្រងទទួលប្រាក់ខែ Salaried supervisor	សរុប total
ភ្នំពេញ Phnom Penh	6	4	10
តាកែវ Takeo	46	0	46
បន្ទាយមានជ័យ Beanteay Meanchey	9	0	9
កំពង់ស្ពឺ Kampong Speu	54	0	54
កំពង់ធំ Kampong Thom	28	0	28
កំពត Kampot	9	0	9
កំពង់ចាម Kampong Cham	10	0	10
ស្វាយរៀង Svay Rieng	20	0	20
សរុប Total	**182**	**4**	**186**

បូករួមទាំងបុគ្គលិកទទួលបានប្រាក់ខែ ចំនួន៣២នាក់ បន្ថែមលើអ្នកចុះទៅធ្វើការសម្រាប់អង្គការម.ព.ជ កំលាំងការងារគឺ ២១៨នាក់ជាសរុបក្នុងឆ្នាំ២០១៨។ ចាប់តាំងពីឆ្នាំ២០១៧ ទំហំបុគ្គលិកធៀបនឹងទំហំការងារមានភាពប្រសើរឡើង ពីអ្នកជំងឺសកម្ម៩៩នាក់ក្នុងមិត្តអប់រំមិត្តម្នាក់ ទៅអ្នកជំងឺសកម្ម១០០នាក់ក្នុងមិត្តអប់រំមិត្តម្នាក់ក្នុងឆ្នាំ២០១៨។ នេះអាចឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពការងារកាន់តែប្រសើរឡើង។

With 32 salaried staff plus the field workers working for MoPoTsyo the workforce is 218 persons in total during 2018. The workload per PE increased since 2017 from 99 active patients per PE to 100 active patienst per PE during 2018. Overall efficiency improved because the number of patients per PE has increased.

.

រូបភាពទី10៖ អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទទួលប្រាក់ខែ Volunteers and salaried staffs



សម្រាប់ហេតុផលដែលបានរៀបរាប់ខាងលើ ចាប់តាំងពីឆ្នាំ២០០៥ ក្នុងចំនោមមិត្តអប់រំមិត្តចំនួន២៤១នាក់ ដែលបានទទួលការបណ្តុះបណ្តាល គឺមានមិត្តអប់រំមិត្តចំនួន១៨២នាក់មកដល់ ឆ្នាំ២០១៨។

The above explains that the number of peer educator in function were 182 in 2018 lower than total of 241 who received training as PE since 2005.

តារាងទី4៖ ចំនួនមិត្តអប់រំមិត្តតាមខេត្តនីមួយៗ ***Numbers of PE by province***

ឆ្នាំ Year	តាកែវ Takeo	ភ្នំពេញ Phnom Penh	ប.មានជ័យ B. Meanchey	កំពង់ស្ពឺ K. Speu	កំពង់ធំ K. Thom	កំពត Kampot	កំពង់ចាមK. Cham	ស្វាយរៀង Svay Rieng	សរុប Total
2010	41	5	6	11	0	0	0	0	**63**
2011	46	5	7	16	0	0	0	0	**74**
2012	56	5	11	24	18	0	0	0	**114**
2013	57	6	11	40	27	0	0	0	**141**
2014	52	5	9	40	28	9	9	0	**152**
2015	52	5	9	40	29	9	11	5	**160**
2016	48	5	9	46	29	9	10	15	**171**
2017	47	5	9	44	27	9	10	20	**171**
2018	46	6	9	54	28	9	10	20	**182**

ឧបសគ្គនៃតុល្យភាពភេទ CHALLENGES TO GENDER BALANCE

យើងបាននឹងកំពុងជួបការលំបាក ធ្វើឱ្យមានតុល្យភាពយែនឌ័រដ៏សមរម្យមួយ សម្រាប់ការជ្រើសរើសមិត្តអប់រំមិត្ត។ ស្វាមីជាច្រើនមិនចង់ឲ្យភរិយារបស់ពួកគេស្ម័គ្រចិត្ត ជាមិត្តអប់រំមិត្ត ហើយការស្វែងរកស្ត្រីមានសមត្ថភាពគ្រប់គ្រាន់ដែលមានបំណងធ្វើការជាមិត្តអប់រំមិត្ត ក៏ជាការលំបាកដែរ។ ផលប្រយោជន៍ទទួលបានពីការងារស្ម័គ្រចិត្តគឺតិចតួច ធ្វើឲ្យការងារជាមិត្តអប់រំមិត្តគឺ អ្នកភាគច្រើនធ្វើដើម្បីតែកិត្តិយស។ រង្វាន់អរូបី មានតម្លៃច្រើនជាងរង្វាន់ជាវត្ថុ។ សមាជិកគ្រួសារអាចនឹងមិនសប្បាយចិត្ត នៅពេលម្តាយមិនសូវយកចិត្តទុកដាក់ទៅលើពួកគេ ហើយរវល់ដើរពេញទីកន្លែង ដើម្បីធ្វើការថែទាំសម្រាប់អ្នកដទៃ។ សម្ពាធបែបនេះ អាចមកពីកូនៗរបស់ពួកគាត់ ឬស្វាមីរបស់ពួកគាត់។ ក្នុងឆ្នាំ២០១៧ មិត្តអប់រំមិត្ត ៣៣%គឺជាស្ត្រី។ ក្នុងឆ្នាំ២០១៨ មិត្តអប់រំមិត្ត ៣២%គឺជាស្ត្រី។ ក៏មានអតុល្យភាពនៅក្នុងភេទនៃអ្នកជំងឺ ប៉ុន្តែវាគឺ មានការផ្ទុយគ្នា សមាមាត្រ១/៣ជាបុរស ធៀបនឹង២/៣នៃស្ត្រី វាមិនបានប្រែប្រួលតាំងពីឆ្នាំ២០០៥។ ក្នុងឆ្នាំ២០១៨ ពួកយើងរកឃើញភាពមិនស៊ីគ្នាដូចខាងក្រោម៖ មាន៣៤%នៃអ្នកទឹកនោមផ្អែមជាបុរស ខណៈ៦៦%នៃមិត្តអប់រំមិត្ត គឺជាបុរស។

It is difficult to reach an appropriate gender balance in both PE's and patients. Many husbands do not want their wife to become a PE. It is also difficult to find women with sufficient capacity who are willing to work as PE. The pay is minimal, making the job of PE something that you do mostly for honor. The immaterial rewards weigh probably more than the material rewards. Members in the household can be unhappy when the mother is not paying as much attention to them, and is busy going around the area in order to care for other people. This type of pressure can come from their children and from their husband. They demand housewife to be free 100% for them. In 2017, 33% PE were female. In 2017, 32% PE were female. There is also an imbalance in the gender of patients…but this is the opposite! The proportion of 1/3 male versus 2/3 female patients has not changed since 2005. In 2018, we find the following mismatch: only 34% of the diabetics are male, while 66% of PE's are male.

រូបភាពទី11៖ មិត្តអប់រំមិត្តតាមភេទក្នុងឆ្នាំ២០១៦ និង២០១៧ PEs by sex in 2016 and 2017



ប្រព័ន្ធថែទាំជំងឺមិនឆ្លង CHRONIC CARE SYSTEM

ភាពចន្លោះប្រហោងព័ត៌មាន រវាងគ្រូពេទ្យផ្តល់សេវា និងអ្នកជំងឺ គឺ ត្រូវបានចងក្រងនៅក្នុងឯកសារស្រាវជ្រាវអន្តរជាតិជាច្រើនទសវត្សមកហើយ។ នៅក្នុងបរិបទប្រទេសកម្ពុជា បណ្តាញមិត្តអប់រំមិត្តសម្រាប់អ្នកជំងឺទឹកនោមផ្អែម និងអ្នកជំងឺលើសឈាម ត្រូវបានបង្កើតឡើង ដើម្បីជួយបង្កើតដំណោះស្រាយជាក់ស្តែង និងបន្តយន្តការនៃការថែទាំប្រកបដោយប្រសិទ្ធភាព។ មិត្តអប់រំមិត្តមាននាទីជាអ្នកកណ្តាលរវាងអ្នកជំងឺ និងប្រព័ន្ធថែទាំសុខភាពសាធារណៈ។ ពួកគេបានយល់ពីភាគីទាំងពីរ និង ជួយ ជាស្ពាននៃទំនាក់ទំនងរវាងភាគីទាំងពីរ ដើម្បីឱ្យមានភាពប្រសើរឡើង។

The information gap between health care providers and patients is well documented in international literature since many decades. In the Cambodian context, so called peer educator networks for diabetes and hypertension are the innovation that helps to create this reality and maintain it. Peer Educators stand as intermediaries between the population and the health care system. They understand both sides and help bridge the poor communication between the two sides.

រូបភាពទី12៖ ប្រព័ន្ធគាំទ្រថែទាំជំងឺរ៉ាំរ៉ៃ របស់បណ្តាញមិត្តអប់រំមិត្ត Surpporting Chronic Care system of PE Network



ដោយសារមើលឃើញ ពីភាពចាំបាច់នៃបណ្តាញមិត្តអប់រំមិត្ត ក្រសួងសុខាភិបាល បានដាក់បញ្ចូលកម្មវិធីបណ្តាញមិត្តអប់រំមិត្តនេះ ទៅក្នុងផែនការយុទ្ធសាស្ត្រជាតិប្រយុទ្ធ និងការពារជំងឺមិនឆ្លងឆ្នាំ២០១៣-២០២០។ ឯកសារគោលនយោបាយនេះ បានចេញផ្សាយជាសាធារណៈនៅដើមខែមេសា ឆ្នាំ២០១៤មកម្លេះ។ ឯកសារនេះ បានផ្តល់នូវគ្រោងផែនការដ៏សំខាន់ សម្រាប់ការអនុវត្តសកម្មភាពទាក់ទងនឹងជំងឺមិនឆ្លង ទោះបីជា វាមិនបានរួមបញ្ចូលបញ្ហាសុខភាពផ្លូវចិត្តដែលវាគួរតែត្រូវបានរួមបញ្ចូលផងដែរ។

For this reason, the Ministry of Health adopted PE Networks as part of its National Strategic Plan for Prevention and Control of Noncommunicable Diseases 2013-2020. This policy document was officially disseminated in early April 2014. It provides the most important framework for implementation of activities related to Chronic Noncommunicable Diseases, although it did not cover Mental Health which it should have included.

រូបភាពទី13៖ តួនាទី និងការទទួលខុសត្រូវរបស់បណ្តាញមិត្តអប់រំមិត្ត Roles and Responsibilities of PE Network



សេវាសុខភាព សម្រួលដោយមិត្តអប់រំមិត្ត HEALTH SERVICES FACILITATED BY PEs

សកម្មភាពចែកតេស្តទឹកនោម DISTRIBUTING URINE GLUCOSE STRIPS

ការស្រាវជ្រាវមនុស្សពេញវ័យ ចាប់ពីអាយុ ១៨ឆ្នាំ ឡើងទៅ គឺជាទូទៅត្រូវបានធ្វើឡើងនៅតំបន់ស្រុកប្រតិបត្តិ នៅពេលដែលអង្គការម.ព.ជបង្កើតបណ្តាញមិត្តអប់រំមិត្ត។ ការស្រាវជ្រាវនេះធ្វើឡើងជា ពីរដំណាក់កាល៖ ទី១ មិត្តអប់រំមិត្ត ផ្តល់មនុស្សម្នាក់ៗនូវស្ត្រីបទឹកនោមមួយដើម និងក្រដាលចង្អុលពណ៌ ដោយមានពន្យល់ជាភាសាខ្មែរអំពីរបៀបប្រើក្រោយ ២ ទៅ៣ ម៉ោងក្រោយហូបអាហារ។ ទី២ ប្រសិនបើមានអ្នកឃើញថា ពណ៌របស់ស្ត្រីបប្រែប្រួល ឬមានចំងល់អំពីតេស្ត អាចស្នើសុំមិត្តអប់រំមិត្តធ្វើតេស្តជាតិស្ករចុងដៃដោយម៉ាស៊ីនស្វ័យប្រវត្តិ ដើម្បីផ្ទៀងផ្ទាត់លទ្ធផលជាតិស្ករ អំពីវត្តមាននៃទឹកនោមផ្អែម។ នៅក្នុងឆ្នាំ២០១៨ យើងមិនបានធ្វើការចែកតេស្តទឹកនោមទេ។

Distrubution of urine glucose strips among adults from 18 years old normally is done in every new OD when MoPoTsyo sets upthe peer educator network. It is done in two stages. First, PE distribute one urine glucose strip per adult with color chart and explanation in khmer on how to use it 2 to 3 hours after lunch. Anyone who observes a change in color of urine test strip or wonders if they are diabetic can ask the PE to do a blood glucose test to confirm whether they really are diabetic or not. In 2018, urine glucose strips are not distributed.

រូបភាពទី14៖ ការធ្វើតេស្តជាតិស្ករក្នុងទឹកនោមដោយខ្លួនឯង ***Yearly self-urine glucose testing***



មិត្តអប់រំមិត្តតាមមូលដ្ឋាន បានចែកស្ត្រីបទឹកនោមទៅឲ្យមនុស្សពេញវ័យដើម្បីធ្វើតេស្ត៍ខ្លួនឯង។ រូបភាពខាងលើ និងខាងក្រោមមានទំនាក់ទំនងជាមួយមនុស្សពេញវ័យ ទើបបានធ្វើស្រាវជ្រាវ ដែលនឹងរៀនពីរបៀបប្រើប្រាស់ស្ត្រីប ដើម្បីធ្វើតេស្ត៍ដោយខ្លួនពួកគេ។

The community-based PE distributes urine glucose strips to adults for self-testing. The figures above and below relate to newly screened adults who learn how to use the strip to test themselves.

រូបភាពខាងក្រោម បង្ហាញពីតួរលេខរួមបញ្ចូលនៃមនុស្សពេញវ័យដែលបានធ្វើតេស្តទឹកនោម ជាមួយបណ្តាញមិត្តអប់រំមិត្ត តាមរយៈការប្រើស្ត្រីបទឹកនោមនាឆ្នាំកន្លងមក។ មនុស្សពេញវ័យ ១,០៣៥,២២៧នាក់ក្នុងប្រទេសកម្ពុជា ឥឡូវកំពុងរស់នៅក្នុងតំបន់មានមិត្តអប់រំមិត្ត។ ជាក់ស្តែង ទោះបីជាលទ្ធផលតេស្តជាតិស្ករតាមរយៈស្ត្រីបទឹកនោម អាចទទួលយកបាន ប៉ុន្តែមានភាពសុក្រិតទាបជាងតេស្តជាតិស្ករចុងដៃ ដោយសារថា ស្ត្រីបទឹកនោមមិនប្រែពណ៌ទោះករណីខ្លះ លើសជាតិស្ករក៏ដោយ (false negative) ខណៈតម្លៃរបស់ស្ត្រីបទឹកនោម គឺថោកជាងប្រហែល១០ ទៅ ១៥ដង។ យើងមិនមានលទ្ធភាពក្នុងផ្តល់តេស្តជាតិស្ករចុងដៃ ក្នុងការស្រាវជ្រាវរកករណីជំងឺទឹកនោមផ្អែម ចំណោមមនុស្សពេញវ័យទូទៅឡើយ ដោយសារវាត្រូវចំណាយខ្ពស់។ ហេតុនេះ យើងនៅបន្តប្រើស្ត្រីបទឹកនោម ក្នុងការស្រាវជ្រាវនេះ ក្នុងការលើកទឹកចិត្តឱ្យប្រជាពលរដ្ឋធ្វើតេស្តដោយខ្លួនឯង និង លើកកម្ពស់ការដឹងយល់របស់ពួកគេអំពីបញ្ហាជំងឺ។ ទោះបែបនេះក្តី ការធ្វើរោគវិនិច្ឆ័យ គឺផ្អែកលើតេស្តជាតិស្ករចុងដៃដោយម៉ាស៊ីនស្វ័យប្រវត្តិ មិនមែនស្ត្រីបទឹកនោមឡើយ។

Adults who buy a strip from the Peer Educator (USD 0.03) to retest themselves in later years are not included. The Figure below indicates the accumulated number of adults who have been made familiar with the Peer Educator Network, through use of urine glucose strips over the years. More than 1,035,227 Cambodian adults are now living in an area with a peer educator. In fact the urine glucose strip is not sensitive giving false negative results but it is 10 to 15 times cheaper than the blood glucose test. We can not afford to distribute free blood glucose test to the whole population because it is too expensive. That is why we continue to distribute free urine glucose test strips to encourage population to self-test and raise their awareness. The diagnosis of diabetes is only made on the basis of blood glucose and never on the basis of urine glucose.

រូបភាពទី15៖ កំណើននៃការគ្រប់ដណ្តប់លើមនុស្សពេញវ័យ Adult population covered by PE networks



សេវាសុខាភិបាល MEDICAL SERVICES

ជាដំបូង យើងនឹងពិនិត្យមើលទៅលើសេវាតេស្តពិសោធន៍វេជ្ជសាស្ត្រ ការប្រើប្រាស់និងថ្លៃចំណាយរបស់សេវាមន្ទីរពិសោធន៍។ បន្ទាប់មកមើលទៅលើការពិគ្រោះជំងឺ ការប្រើប្រាស់សេវាពិគ្រោះជំងឺ (ដូចជាការទទួលបាននូវវេជ្ជបញ្ជាពីព្រោះរាល់ការពិគ្រោះជំងឺ គ្រូពេទ្យបានចេញវេជ្ជបញ្ជា១ ដែលអាចប្រើប្រាស់បានម្តងហើយម្តងទៀតដើម្បីទិញថ្នាំនៅឱសថស្ថាន) ហើយបន្ទាប់មកទៀត យើងមើលអំពីការចំណាយសម្រាប់អ្នកជំងឺ លើការអនុវត្តការព្យាបាល និងការអនុវត្តតាមវេជ្ជបញ្ជាខាងក្រោមនេះ។ ហើយយើងក៏ធ្វើការ ពិនិត្យមើលដែរ ទៅលើការគ្រប់គ្រងមូលនិធិបង្វិលទុនឱសថ ដែលបានធ្វើកិច្ចសន្យាជាមួយ ទាំងឱសថស្ថានរដ្ឋនិងឯកជន ក្នុងការចែកចាយឱសថដល់សមាជិកអង្គការ ដោយប្រើប្រាស់វិក្កយបត្របោះពុម្ពរួចជាស្រេច នៅពេលដែលសមាជិកមកទិញថ្នាំ។ អង្គការម.ព.ជ បានចាប់ផ្តើមរៀបចំសេវាតេស្តពិសោធន៍វេជ្ជសាស្ត្រ នៅឆ្នាំ២០០៩។

We review first the laboratory services, their utilization and cost, then the Medical. Consultations, their utilization (discussed as access to prescription because every medical consultation results in a prescription that can be used repeatedly to buy prescribed medicines at the pharmacy), and then the cost to the patient of adhering to the treatment and adherence. This is followed by a review of the Revolving Drug Fund that is managed through contracted private and public pharmacies that dispense the medicines using preprinted invoices, paid for by our members. MoPoTsyo began to organise laboratory services in 2009.

សេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រ LABORATORY SERVICE

សេវាមន្ទីរពិសោធន៍មានគុណប្រយោជន៍សំខាន់៣៖

1) ផ្តល់ព័ត៌មាន និងជំរុញទឹកចិត្តអ្នកជំងឺដើម្បីស្វែងរកការថែទាំជំងឺ និងទទួលបានអត្ថប្រយោជន៍ពីការប្រើប្រាស់សេវាពិគ្រោះជំងឺ និងការអនុវត្តតាមវេជ្ជបញ្ជាលើឱសថដែលគ្រូពេទ្យផ្តល់ឱ្យ។ បើគ្មានលទ្ធផលមន្ទីរពិសោធន៍នោះទេ អ្នកជំងឺផ្អែកលើអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ ដើម្បីដឹងពីសុខភាពតែប៉ុណ្ណោះ។ បញ្ហានេះអាចបង្កគ្រោះថ្នាក់ដល់អ្នកជំងឺ ដោយហេតុថាជំងឺមួយចំនួនគឺមានលក្ខណៈស្ងៀមស្ងាត់ និងមិនបង្ហាញរោគសញ្ញា។

2) វេជ្ជបណ្ឌិតត្រូវការលទ្ធផលមន្ទីរពិសោធន៍ ដើម្បីចេញវេជ្ជបញ្ជាឱសថ ដែលសមស្របសម្រាប់អ្នកជំងឺ និងដើម្បីកែតម្រូវវេជ្ជបញ្ជា ឬធ្វើការបញ្ជូនអ្នកជំងឺបន្ត។

3) មន្ត្រីសុខភាពសាធារណៈត្រូវការមើលទៅលើលទ្ធផលទាំងនេះដើម្បីអាចធ្វើការវិភាគ ថាតើតម្រូវការក្នុងការព្យាបាលកំពុងត្រូវបានបំពេញតាមយ៉ាងសមស្របឬទេ តាមរយៈគ្រូពេទ្យចេញវេជ្ជបញ្ជា និងត្រួតពិនិត្យអំពីប្រសិទ្ធភាពនៃការព្យាបាលនៃវេជ្ជបញ្ជា។

Laboratory service is useful for 3 main reasons:

1) It helps to inform and motivate patients to seek medical care and make use of the medical consultation service and adhere to their medication. Without a laboratory, people rely on their feeling of well-being. This can be treacherous as many conditions are “silent” and a-symptomatic.

2) The Doctor needs the laboratory result for prescription of appropriate medication for the patient and for adaptation of the prescription or referral.

3) Public Health authorities need access to these results to be able to analyse whether people’s therapeutic needs are being adequately met by prescribing physicians and monitor the effectiveness of prescription therapy.

មានអ្នកជំងឺចំនួន ៤,៩៨៣នាក់ ដែលបានប្រើសេវាមន្ទីរពិសោធន៍យ៉ាងតិចម្តងក្នុងឆ្នាំ២០១៨ ខណៈដែលក្នុងឆ្នាំ២០១៧ មានចំនួន ៣,៩៤០នាក់។ យើងបានរក្សាចំនួនអ្នកបច្ចេកទេសមន្ទីរពិសោធន៍ ដោយមានអ្នកធ្វើការពេញម៉ោងចំនួន ៣នាក់ និង ១នាក់ធ្វើការពាក់កណ្តាលថ្ងៃ។ ដូចដែលបង្ហាញក្នុងតារាងខាងក្រោម សមាមាត្រអ្នកជំងឺតាមក្រុមអាយុដែលមិនបានបញ្ចូល ពេលស្ទង់មតិថ្នាក់ជាតិឆ្នាំ២០១០ (STEP SURVEY) បាននឹងកំពុងប្រើសេវាមន្ទីរពិសោធន៍របស់យើង ដោយពួកគេបានចុះឈ្មោះជាសមាជិក។ សេវាមន្ទីរពិសោធន៍ត្រូវបានប្រើប្រាស់ដោយសមាជិកចាស់ និងក្មេងដែលបានចុះឈ្មោះជាមួយអង្គការម.ព.ជ។ សមាមាត្រនៃមនុស្សវ័យចំណាស់ (អាយុ៦៥ឆ្នាំឬចាស់ជាង) ប្រើប្រាស់សេវាមន្ទីរពិសោធន៍មានការកើនឡើងបន្តិចពី ២៣% ក្នុងចំណោមអ្នកប្រើប្រាស់ចំនួន ៣,៩៤០នាក់ ក្នុងឆ្នាំ២០១៧ ទៅ ២៧% ក្នុងចំណោមអ្នកប្រើប្រាស់ចំនួន ៤,៩៨៣នាក់ ក្នុងឆ្នាំ២០១៨។ មានសមាជិកចំនួន ៤៣% បានប្រើប្រាស់សេវាមន្ទីរពិសោធន៍ ២ដងក្នុងមួយឆ្នាំ។ រូបភាពខាងក្រោមពិតជាមានសារៈសំខាន់ដែលអាចឱ្យយើងបង្ហាញពីអ្នកដែលបានប្រើប្រាស់សេវាមន្ទីរពិសោធន៍ ធៀបទៅអ្នកក្នុងក្រុមអាយុរបស់ពួកគេ ដែលបានចុះឈ្មោះក្នុងប្រព័ន្ធទិន្នន័យវាយតម្លៃ។ វិធីនេះអាចឱ្យយើងឃើញថា តើក្រុមអាយុមួយណាមានចំនួនអ្នកដែលប្រើប្រាស់សេវាច្រើនជាងក្រុមផ្សេងៗ ទៀត។ យើងឃើញថា ការប្រើប្រាស់សេវាសម្រាប់មនុស្សចំណាស់អាយុច្រើនជាង ៦៥ឆ្នាំមានចំនួនតិចតួច។

There were 4,983 patients who used the laboratory at least once during 2018, compared to 3,940 in 2017. We keep the number of laboratory technicians to 3 Full Timers and 1 Part Timer. As can be seen in the figure below, a substantial proportion of people from the age groups in which the prevalence of NCD was not measured during the 2010 national STEP survey make use of our laboratory services as members with chronic disease: these services are used by Elderly people and younger persons who are member of MoPoTsyo. The proportion of elderly people (65 years or older) using the laboratory slightly increased from 23% among 3,940 users in 2017 and 27% among 4,983 users in 2018. 43% of members used the lab twice. The figure below is now more meaningful as we show those who have access compared to how many patients there are in their own age groups in the assessment data.This way we can keep an eye on which age group is crowding out another one. We can see that access for the elderly is an issue among those over 65 years, unsurprisingly.

រូបភាពទី 16៖ ឱកាសប្រើប្រាស់សេវាមន្ទីរពិសោធន៍តាមក្រុមអាយុ Access to lab-services by different age groups



រូបភាពទី 17៖ ឱកាសប្រើប្រាស់សេវាមន្ទីរពិសោធន៍សម្រាប់មនុស្សចាស់ Access to the lab-services for elderly



មួយវិញទៀត បើយោងទៅតាមសមាមាត្រ សមាជិកជាស្ត្រីភាគច្រើនបានប្រើប្រាស់សេវានៃអង្គការម.ព.ជ ហើយចំនួនស្ត្រី ក៏បានធ្វើការប្រើប្រាស់សេវាមន្ទីរពិសោធន៍ច្រើនជាងបុរសដែរ។ ក្នុងន័យនេះ ឱកាសប្រើសេវាមន្ទីរពិសោធន៍សម្រាប់ស្ត្រីនិងបុរសគឺមិនស្មើគ្នានោះទេ។ ប្រព័ន្ធទិន្នន័យ បានបង្ហាញឱ្យឃើញថា សមាជិកដែលបានចុះឈ្មោះជាមួយអង្គការម.ព.ជ មានស្ត្រី ២/៣ និងបុរស ១/៣ នៃចំនួនសមាជិកសរុបក្នុងឆ្នាំ ២០១៧ ហើយវាមិនមានប្រែប្រួលឡើយ ក្នុងឆ្នាំ២០១៨។

Moreover, as proportionally more women use the services of MoPoTsyo, they also make more use of the lab. In that sense, the access for women and men to the laboratory services is not equal. Data system showed that members registered in MoPoTsyo with women 2/3 and men 1/3 of the total in 2017. This still remains mostly unchanged in 2018.

តារាងទី 5៖ សមភាពតាមយេនដ័រ ក្នុងការទទួលសេវាមន្ទីរពិសោធន៍ Equal access to the lab-services by gender

ភេទ	ចំនួន	ភាគរយ
បុរស	1840	37%
ស្ត្រី	3143	63%
សរុប (ឆ្នាំ2018)	*4983*	*100%*

យើងចង់ឲ្យសមាជិកម្នាក់ៗ ប្រើប្រាស់សេវាតេស្តមន្ទីរពិសោធន៍វេជ្ជសាស្ត្រ ឱ្យបានម្តង/ឆ្នាំ ខណៈពេលដែលសមាជិកផ្សេងទៀត ដែលមានលទ្ធភាពអាចប្រើប្រាស់សេវានេះ ច្រើនជាងម្តង/ឆ្នាំ។ ម្យ៉ាងវិញទៀត យើងពិតជាសប្បាយចិត្តដែលឃើញថា សមាជិកដែលប្រើសេវាមន្ទីរពិសោធន៍មានការកើនឡើងស្ទើររាល់ឆ្នាំ។ ទោះបីការពិតនោះថា សេវានេះត្រូវបានផ្តល់ស្ទើរតែនៅថ្លៃដើមក៏ដោយ។ វាពិតជាមានប្រយោជន៍សម្រាប់អ្នកជំងឺក្រីក្រ ក្នុងការទទួលបានបដិភាគសម្រាប់ថ្លៃសេវាមន្ទីរពិសោធន៍ ដើម្បីពួកគាត់មានឱកាសប្រើប្រាស់សេវានេះផងដែរ។

We want every patient to use laboratory services at least once per year. On the other hand, it is encouraging to see how the number of patients who uses the laboratory service increases yearly. Despite the fact that this service is provided almost at the cost price, it seems worthwhile to subsidize the service for the poorest patients, so they can access the service as well.

រូបភាពទី១៥៖ ការប្រើប្រាស់សេវាមន្ទីរពិសោធន៍ និងថ្លៃចំនាយ ***Lab-services usage and cost***



តារាងទី៩៖ ថ្លៃចំនាយបរិក្ខារមន្ទីរពិសោធន៍កំឡុងរយៈពេល៥ឆ្នាំ ***Laboratory costs based on 5-year life of machines***

Fixed Cost of Laboratory Program		Year				
Machines	Purchase Price	2014	2015	2016	2017	2018
HumaLyzer Junior	$2,854	$571	$0	$0	$0	$0
HumaLyzer 3000 (A)	$5,800	$1,160	$1,160	$0	$0	$0
CombiLyzer	$1,500	$300	$300	$300	$0	$0
HumaScope	$950	$190	$190	$190	$0	$0
HumaLyzer 3000 (B)	$5,800	$1,160	$1,160	$1,160	$1,160	$0
HumaLyte Plus3	$4,200	$840	$840	$840	$840	$840
		$4,221	$3,650	$2,490	$2,000	$840
Expenditure of Laboratory Program						
	Expenditure on Fixed Cost	$4,221	$3,650	$2,490	$2,000	$840
	Expenditure on Variable Cost	$18,051	$34,055	$34,291	$41,072	$49,248
	Total	$22,272	$37,705	$36,781	$43,072	$50,088
Cost per Lab Result						
	Total Fixed Cost 2014-2018	$13,201				
	Total Variable Cost 2014-2018	$176,717				
	Total Fix and Variable Cost 2018	$50,088				
	Number of Lab Results	7126				
	Cost Per Result	$9				
	Cost Per Result Paid by Member	$11				

ឈ្មោះតេស្តនីមួយៗ ត្រូវបានសរសេរទាំងជាភាសាខ្មែរនិងភាសាអង់គ្លេស ក៏ដូចជាតម្លៃធម្មតា និងការណែនាំអំពីលទ្ធផល ដើម្បីសម្រួលឱ្យអ្នកជំងឺក្នុងការយល់ដឹងលើភាពធ្ងន់ធ្ងរនៃស្ថានភាពជំងឺរបស់ពួកគាត់។

ការបង្ហាញលទ្ធផលមន្ទីរពិសោធន៍ មានគោលបំណងជួយអ្នកជំងឺ បានយល់អំពីលទ្ធផលតាមរយៈមិត្តអប់រំមិត្ត។ មូលដ្ឋានទិន្នន័យបច្ចុប្បន្ន អាចឲ្យយើងអាចបោះពុម្ព (Print) លទ្ធផល ៣ដងចុងក្រោយរបស់អ្នកជំងឺក្នុងក្រដាសតែមួយ។ ដូច្នេះគ្រប់គ្នាអាចមើលឃើញភ្លាម និងអាចប្រៀបធៀបពីនិន្នាការនៃលទ្ធផលដែលធ្លាប់មានកន្លងមក។ ទំរង់លទ្ធផលបែបនេះ អាចជួយសន្សំពេលវេលាដល់វេជ្ជបណ្ឌិតពេលពិគ្រោះជំងឺ។ សូមមើលឧទាហរណ៍ខាងក្រោម។

The name of each test is written both in Khmer and English, as well as the normal value and a basic indication of what the test measures to facilitate patient understanding of disease severity.

The presentation of results is to help patients understand and peer educators explain the results to the patients. The database allows us to print the last three lab profiles of the same patient. This helps everyone to see in one glance what is happening with the trend of each indicator. This lab profile saves the Doctor time during the medical consultation, see the example below;



មណ្ឌល ព័ត៌មាន ជំងឺ
Patient Information Centre
MoPoTsyo

ផ្ទះលេខ 9E ផ្លូវលេខ 3C
ភូមិទ្រា១ សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ រាជធានីភ្នំពេញ
លេខទូរស័ព្ទ 023 883 228

ផ្តល់សេវាជួសជុលស្រ្តមិនស្វែងរកប្រាក់ចំណេញ ផ្នែកមន្ទីរពិសោធន៍ (Not-For-Profit Medical Laboratory Unit)

លទ្ធផលតេស្តមន្ទីរពិសោធន៍
(Laboratory Test Result)

លេខកូដសមាជិក (Patient Code)	:	កាលបរិច្ឆេទបូមឈាម (Sampling Date)	: 08-Aug-2018
ឈ្មោះសមាជិក (Patient Name)	:	កាលបរិច្ឆេទលទ្ធផល (Result Date)	: 09-Aug-2018
ភេទ (Sex)			
អាយុ (Age)		លេខប័ណ្ណស្នើសុំ (Request No)	: 038376
ផ្សេងៗ (Other)		លេខលទ្ធផល (Result No)	: 201713944

ល.រ No	ហិយាយតេស្ត Test Description	2017	07-2017	08-08-2018	ឯកតា Unit	គោលដៅកំណត់ធម្មតា Normal Range
I -	BLOOD TEST RESULT					
1	អេច ប៊ី អេ វ៉ែន ស៊ី (HbA1c)	11.6	10.6	9.2	%	ចន្លោះពី 4.0 ទៅ 6.0% (សំរាប់អ្នកគ្មានជំងឺទឹកនោមផ្អែម) ចន្លោះពី 6.5 ទៅ 7.0% (សំរាប់អ្នកជំងឺប្រើថ្នាំទឹកនោមផ្អែម)
2	ស្ករក្នុងឈាមមុនហូបអាហារ (Fasting Blood Sugar)	181	128	135	mg/dl	ចន្លោះពី 60 ទៅ 109 mg/dl បង្ហាញថាដូចអ្នកគ្មានជំងឺទឹកនោមផ្អែម ចន្លោះពី 110 ទៅ 125 mg/dl បង្ហាញថាអ្នកត្រៀមមានជំងឺទឹកនោមផ្អែម ច្រើនជាងរឺស្មើ 126 mg/dl បង្ហាញថាអ្នកមានជំងឺទឹកនោមផ្អែម
3	ប៉ូតាស្យូម (Potassium)	4.4	5.2	4.6	mmol/l	ចន្លោះពី 3.5 ទៅ 5.0 មីលីមូលក្នុងមួយលីត្រ
4	សូដ្យូម (Sodium)	139	142	147	mmol/l	ចន្លោះពី 135 ទៅ 145 មីលីមូលក្នុងមួយលីត្រ
5	ក្លរ (Chloride)	104	104	105	mmol/l	ចន្លោះពី 98 ទៅ 108 មីលីមូលក្នុងមួយលីត្រ
6	ទ្រីគ្លីសេរីដ (Triglyceride)	264	412	115	mg/dl	តិចជាង 150 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
7	កូលេស្តេរ៉ុលសរុប (Total Cholesterol)	212	202	232	mg/dl	តិចជាង 200 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
8	អេច ដេ អិល (HDL Cholesterol)	36	35	57	mg/dl	ចន្លោះពី 40 ទៅ 70 មីលីក្រាមក្នុងមួយដេស៊ីលីត្រ
9	អិល ដេ អិល (Estimated LDL Cholesterol)	123		152	mg/dl	ចន្លោះពី 62 ទៅ 99 mg/dl អត់មានបញ្ហាខ្ពស់មិនល្អ ចន្លោះពី 100 ទៅ 159 mg/dl ត្រៀមមានបញ្ហាខ្ពស់មិនល្អ ច្រើនជាងរឺស្មើ 160 mg/dl មានបញ្ហាខ្ពស់មិនល្អ
10	ត្រង់សាមីនាស (Transaminase SGPT)	31	38	29	U/L	ចន្លោះពី 7 ទៅ 50 ឯកតាក្នុងមួយលីត្រ

Office is located next to SorLa Primary School in Borey SorLa
#9E Street 3C, Phum Trea 1, Stung Meanchey Commune, Phnom Penh, Cambodia. Contact Tel: 012-800 322, 023 883 228
Mail: P.O.Box 840 Phnom Penh, Cambodia, Email: mopotsyo@gmail.com
http://www.mopotsyo.org

មណ្ឌល ព័ត៌មាន ជំងឺ

Patient Information Centre
MoPoTsyo

ផ្ទះលេខ 9E ផ្លូវលេខ 3C
ភូមិទ្រា1 សង្កាត់ស្ទឹងមានជ័យ
ខណ្ឌមានជ័យ រាជធានីភ្នំពេញ
លេខទូរស័ព្ទ 023 883 228

ផ្តល់សេវាជួសជុលស្រាស្ត្រមិនស្វែងរកប្រាក់ចំណេញ ផ្នែកមន្ទីរពិសោធន៍ (Not-For-Profit Medical Laboratory Unit)

លទ្ធផលតេស្តមន្ទីរពិសោធន៍
(Laboratory Test Result)

លេខកូដសមាជិក (Patient Code)	
ឈ្មោះសមាជិក (Patient Name)	រ
ភេទ (Sex)	
អាយុ (Age)	
ផ្សេងៗ (Other) :	

កាលបរិច្ឆេទបូមឈាម (Sampling Date)	: 08-Aug-2018
កាលបរិច្ឆេទលទ្ធផល (Result Date)	: 09-Aug-2018
លេខប័ណ្ណស្នើសុំ (Request No)	: 038376
លេខលទ្ធផល (Result No)	: 201713944

ល.រ No	បរិយាយតេស្ត Test Description	28-03-2017	25-07-2017	08-08-2018	ឯកតា Unit	គោលដៅកំណត់ធម្មតា Normal Range
11	ត្រង់សាមីនាស (Transaminase SGOT)	30	36	30	U/L	ចន្លោះពី 10 ទៅ 40 ឯកតាក្នុងមួយលីត្រ
12	ក្រេអាទីនីន (Creatinine)	0.8	0.8	0.8	mg/dl	តិចជាង 1.1 មីលីក្រាមក្នុងមួយដេស៊ីលីត្រ សំរាប់ស្ត្រី តិចជាង 1.2 មីលីក្រាមក្នុងមួយដេស៊ីលីត្រ សំរាប់បុរស
13	អ៊ី ជី អ៊ែហ្ស អរ (eGFR)	>60	>60	>60	mL/min	ធំជាង 60 មីលីលីត្រក្នុងមួយនាទី
14	យូរិកអាស៊ីត (ក្នុងឈាម) (Uric Acid in Serum)			4.2	mg/dl	- ចន្លោះពី2.4 ទៅ 6.1 មីលីក្រាមក្នុងមួយដេស៊ីលីត្រឈាម សំរាប់ស្ត្រី , - ចន្លោះពី 3.4 ទៅ 7.2 មីលីក្រាមក្នុងមួយដេស៊ីលីត្រឈាម សំរាប់បុរស
15	ហេភេតធ្លើម C (HCV Bioline)			-		- អវិជ្ជមាន + វិជ្ជមាន
II -	URINE TEST RESULT					
16	ប្រូតេអ៊ីនក្នុងទឹកនោម (Proteinuria)	-	-	-	សញ្ញា	- គ្មានប្រូតេអ៊ីនក្នុងទឹកនោម -+ សង្ស័យមានប្រូតេអ៊ីនក្នុងទឹកនោម + រឺ ++ រឺ +++ រឺ ++++ មានប្រូតេអ៊ីនក្នុងទឹកនោម (សូមធ្វើតេស្តអោយបាន 3ដងក្នុង3ខែ ដើម្បីបញ្ជាក់ថាអ្នកមានប្រូតេអ៊ីនក្នុងទឹកនោម)
17	អាល់ប៊ូមីនក្នុងទឹកនោម (Albuminuria)	10	10	10	mg/l	តិចជាង 20 មីលីក្រាមក្នុងមួយលីត្រ
18	ក្រេអាទីនីនក្នុងទឹកនោម (Urine Creatinine)	50	50	100	mg/dl	ចន្លោះពី 10 ទៅ 300 មីលីក្រាមក្នុងមួយដេស៊ីលីត្រ

Office is located next to SorLa Primary School in Borey SorLa
#9E Street 3C, Phum Trea 1, Stung Meanchey Commune, Phnom Penh, Cambodia. Contact Tel: 012-800 322, 023 883 228
Mail: P.O.Box 840 Phnom Penh, Cambodia, Email: mopotsyo@gmail.com
http://www.mopotsyo.org

សេវាពិគ្រោះជំងឺ CONSULTATION SESSION

ការពិគ្រោះជំងឺ ត្រូវបានរៀបចំដោយអង្គការ ម.ព.ជ នៅកន្លែងសាធារណៈចំនួន១៣ (មិនរាប់បញ្ចូលមណ្ឌលសុខភាពបុសខ្ទុរ) ក្នុងស្រុកប្រតិបត្តិចំនួន១២ ភាគច្រើននៅមន្ទីរពេទ្យមូលដ្ឋានសាធារណៈជនបទ (CPA1 or CPA2 and MPA) ក្នុងបន្ទប់នៅមន្ទីរពេទ្យដែលទុកទំនេរ ឬទុកសម្រាប់ការណាត់ជួបរាល់ ១សប្តាហ៍ ឬ២សប្តាហ៍ម្តង។ ការណាត់មានរយៈពេលកន្លះថ្ងៃ ដែលពេលនោះអ្នកជំងឺចំនួន៣០ ទៅ ៥0 នាក់ ទទួលការពិគ្រោះជំងឺ។ សម្រាប់ការពិគ្រោះជំងឺចំនួន ២៦,៣២៤ដង ក្នុងឆ្នាំ២០១៨។ អង្គការម.ប.ជ មានកិច្ចសន្យាជាមួយវេជ្ជបណ្ឌិតមូលដ្ឋាន ដោយមានការបណ្តុះបណ្តាលរៀបចំដោយពីអង្គការ ម.ព.ជ ទទួលធ្វើការពិគ្រោះជំងឺ សម្រាប់សមាជិករបស់មិត្តអប់រំមិត្ត។ វេជ្ជបណ្ឌិតម្នាក់ក្នុងចំនោមពួកគេជួបម្តង ឬបួនដងក្នុង១ខែសម្រាប់ការពិគ្រោះជំងឺរយៈពេល១ព្រឹកជូនសមាជិកបណ្តាញមិត្តអប់រំមិត្ត។

ផ្នែកគ្រប់គ្រងកម្មវិធីរបស់អង្គការម.ព.ជ រៀបចំការណាត់ជួបសម្រាប់ការពិគ្រោះជំងឺទាំងនេះ អាស្រ័យទៅលើព័ត៌មានទទួលបាន តាមរយៈបណ្តាញមិត្តអប់រំមិត្តពីតម្រូវការ ក្នុងន័យផ្សេងទៀតគឺ បរិមាណតម្រូវការ។ ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៧មក កាលវិភាគនៃការពិគ្រោះជំងឺ គឺត្រូវបានរៀបចំ ដោយមានការសម្រេចចិត្តពីវេជ្ជបណ្ឌិតនៅមូលដ្ឋានរបស់មន្ទីរពេទ្យ/មណ្ឌលភាព។ មិត្តអប់រំមិត្ត ធ្វើកិច្ចការងារដូចជា គ្រប់គ្រងក្រុមមនុស្ស ចុះឈ្មោះអ្នកជំងឺ រៀបចំបែបបទរដ្ឋបាល ។ល។ ជាកិច្ចការដែលក្នុងប្រទេសដទៃ ត្រូវធ្វើដោយគិលានុប្បដ្ឋាក និងបុគ្គលិកជំនាញរបស់មន្ទីរពេទ្យ។ ពេលខ្លះ ការណាត់ជួបនៅពេលព្រឹក ពេលខ្លះនៅពេលរសៀល មិនដែលពេញមួយថ្ងៃនោះទេ។ ភាគច្រើននៃវេជ្ជបណ្ឌិតទាំងនេះ ជាមន្ត្រីរាជការ។ គឺមានអត្ថប្រយោជន៍ផ្សេងៗគ្នា ក្នុងការអនុញ្ញាតិឲ្យមិត្តអប់រំមិត្តចូលរួមការគ្រប់គ្រងលើការផ្តល់សេវាឲ្យសមាជិករួមមាន ប៉ុន្តែមិនកំណត់ចំពោះ៖

1) បន្ថយថ្លៃចំណាយសរុប ពីព្រោះពេលវេលារបស់គិលានុប្បដ្ឋាក ថ្លៃជាងពេលវេលារបស់មិត្តអប់រំមិត្ត។
2) អ្នកជំងឺជឿទុកចិត្ត និងស្និតស្នាលជាមួយមិត្តអប់រំមិត្ត ពីព្រោះពួកគាត់ស្គាល់ពួកគេច្បាស់ និងរស់នៅក្នុងសហគមន៍តែមួយ។

Medical consultations are organised by MoPoTsyo in 13(excluded Bos Khnor HC) public facilities in 12 Operational Districts, mostly at rural referral hospitals (CPA1 or CPA2) in a room at the hospital that is made available or kept available for these weekly or 2-weekly sessions. A session lasts half a day during which some 30 to 50 patients receive medical consultation. For 26,324 medical consultations in 2018, MoPoTsyo contracted with Doctors at the local health facilities to get training and provide consultation to the registered patients. Every one of them (doctors) consults once or a couple of times per month, during a half day(morning/afternoon).

MoPoTsyo's program department plans these sessions, based on information it receives through its PEN about the size of need, in other words "the volume of the demand". Since middle of 2017, the consultation schedules are agreed with the local government doctors at the Referral Hospitals. The PE's perform tasks such as crowd control, registration, preparing, administration etc., tasks that in other countries is done by nurses and other professional hospital staff. Sometimes the session is in the morning, sometimes in the afternoon, but never the whole day. Most of these doctors are nowadays government staffs. There are different advantages in letting the PE's join in the management of the service delivery to the members including but not limited to:

1. Lower overall cost because nurse time is much more expensive than PE time.
2. Patients trust and feel closed to the PE's because they know them personally and live same community

3) មិត្តអប់រំមិត្តអាចស្គាល់ពីការព្យាបាល រឺការណែនាំរបស់គ្រូពេទ្យ ជារឿយៗ វាមានប្រយោជន៍ ប្រសិនបើមិត្តអប់រំមិត្តនិយាយម្តងហើយម្តងទៀតនូវដំបូន្មានរបស់គ្រូពេទ្យ ពេលត្រលប់ទៅសហគមន៍វិញ។

ដោយសារជាញឹកញាប់ អ្នកជំងឺមិនសូវចងចាំនូវអ្វីដែលគ្រូពេទ្យបានប្រាប់ពួកគេ កាលណាពួកគេនៅក្រៅ ឬត្រលប់ទៅផ្ទះវិញ ដូច្នេះតួនាទីមិត្តអប់រំមិត្តនៅតាមសហគមន៍បានរួមចំណែកជាច្រើនសំរាប់អ្នកជំងឺ ដូចជា ៖

1. ឥទ្ធិពល ការជំរុញលើកទឹកចិត្ត និង ភាពម្ចាស់ការនៃសេវាដោយមិត្តអប់រំមិត្ត
2. មិត្តអប់រំមិត្តផ្តល់ការការពារលើការបាត់បង់ភាពស៊ីចង្វាក់គ្នា រវាងការចេញវេជ្ជបញ្ជាដោយគ្រូពេទ្យ និងការចែកចាយថ្នាំតាមរយៈមូលនិធិទុនបង្វិល ធ្វើដោយប្រុងប្រយ័ត្ន និងការត្រួតពិនិត្យលើសេវា។
3. មិត្តអប់រំមិត្តមានពេលវេលា/ម៉ោងងាយស្រួលសម្រាប់ការពិគ្រោះគ្នា(ចុងសប្តាហ៍)ក្រៅម៉ោងធ្វើការ
4. ការផ្តល់សេវាគឺមានលក្ខណៈសាមញ្ញច្រើន និងភាពសប្បាយច្រើនសម្រាប់គ្រប់ៗគ្នា។
5. មានមិត្តអប់រំមិត្តម្នាក់បង្កើតឲ្យមានបរិយាកាសការងារសមតាមបំណងសម្រាប់វេជ្ជបណ្ឌិត

ក្នុងឆ្នាំ២០១៨ ចំនួននៃការពិគ្រោះបានកើនឡើងប្រមាណ ២១% ឬកើនពី ២១,៦៧៩ (២០១៧) ទៅការពិគ្រោះចំនួន ២៦,៣២៤ (២០១៨)។ ចំនួនសេវានៃការពិគ្រោះជំងឺធ្វើដោយវេជ្ជបណ្ឌិត បានកើនឡើងដល់ ៩% ពីចំនួន៥៤០ពេលទៅ ៥៨៩ពេល។ ដូច្នេះ ចំនួនអ្នកជំងឺក្នុងមួយពេលកើនឡើងពី ៤០នាក់ ក្នុងឆ្នាំ២០១៧ មកដល់ ៤៥នាក់ក្នុងមួយវេនក្នុងឆ្នាំ២០១៨។ មានន័យថា ការចំនាយពេលវេលាថយចុះ រវាងគ្រូពេទ្យ និងអ្នកជំងឺ។ ពួកយើងត្រូវវិភាគជារៀងរាល់ឆ្នាំ ប្រសិនបើមូលហេតុនេះ កំពុងបង្កើតជាបញ្ហា ឬគ្រាន់តែបង្ហាញពីការកើនឡើងនូវប្រសិទ្ធភាព៖ ជាឧទាហរណ៍ ធ្វើឲ្យប្រសើឡើងនូវការប្រើបាននៃលទ្ធផលមន្ទីរពិសោធន៍ ទាមទារយៈពេលតិចសម្រាប់គ្រូពេទ្យក្នុងការសម្រេចចិត្ត។ ជាចុងក្រោយ វាអាស្រ័យថាតើ វេជ្ជបណ្ឌិតមួយណាសម្រេចបានលទ្ធផលល្អជាងគេ ប្រសិនពួកយើងអាចដាក់វាឲ្យនៅដាច់ដោយដោយឡែកពីកត្តាផ្សេងៗ។ ពួកយើងបានធ្វើការជាមួយវេជ្ជបណ្ឌិត

3. PE's can hear the doctor's treatment or advice. Often it is helpful if PE's repeat and repeat again the advice of the doctor, later back in the community.

Because very often patients do not remember what the doctor told them once they are outside or back home again, so through their roles in community the peer educator help patients a lot:

1. Prestige, motivation, and ownership of the service by the PE's
2. PE's provide a safeguard against loss of coherence between prescription by doctors and dispensing of medication through the RDF, by being vigilant and monitoring services.
3. PE's offer convenient hours/time for consultation (weekends) outside working hours.
4. Service provision is more casual and more fun for everyone.
5. Having a PE creates a more satisfactory work environment for the Doctor.

During 2018, the number of consultations increased from 21,679 consultations (2017) to 26,324 consultations in total (in 2018), an increase by 21%. The number of consultation sessions increased by 9% from 540 to 589. Therefore, the number of patients per session increased from 40 in 2017 to 45 patients per session in 2018. This means less time spent between the doctor and the patient. We have to analyse every year if this issue is causing problems or simply represents a gain in efficiency - for example to better availability of laboratory results - requiring less time for the physician to come to a decision. Ultimately it depends on "which doctor achieves the best outcomes" if we can isolate this from other factors. We have been working with 32 local doctors

មូលដ្ឋានចំនួន៣២នាក់ ដើម្បីផ្តល់សេវាពិគ្រោះ ២៦,៣២៤ ដង ទៅឱ្យសមាជិករបស់ពួកយើង។ វា ជាគំរូសហការផ្តល់សេវា រវាងអង្គការម.ព.ជ និងមន្ទីរពេទ្យ/មណ្ឌលសុខភាពមូលដ្ឋាន ក្រោយពីវេជ្ជបណ្ឌិតមកពីមូលដ្ឋានសុខាភិបាលទាំងនោះ មានទទួលការបណ្តុះបណ្តាលហើយ។

to deliver 26,324 consultation services to our members. This is a cooperation model of service between MoPoTsyo and local health facilities after the local doctors received the training on medical consultation for diabetes and hypertension.

តារាងទី 7: សេវាពិគ្រោះជាមួយវេជ្ជបណ្ឌិតក្នុងឆ្នាំ២០១៨ Medical consultations by doctors in 2018

គ្រូពេទ្យ	ចំនួនពិគ្រោះជំងឺ	ភាគរយ
គ្រូពេទ្យ 1 Dr 1	62	0.24%
គ្រូពេទ្យ 2 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 2 (RH/HC)	517	1.96%
គ្រូពេទ្យ 3 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 3 (RH/HC)	191	0.73%
គ្រូពេទ្យ 4 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 4 (RH/HC)	302	1.15%
គ្រូពេទ្យ 5 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 5 (RH/HC)	1193	4.53%
គ្រូពេទ្យ 6 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 6 (RH/HC)	57	0.22%
គ្រូពេទ្យ 7 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 7 (RH/HC)	1	0.00%
គ្រូពេទ្យ 8 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 8 (RH/HC)	186	0.71%
គ្រូពេទ្យ 9 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 9 (RH/HC)	2037	7.74%
គ្រូពេទ្យ 10 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 10 (RH/HC)	2462	9.35%
គ្រូពេទ្យ 11 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 11 (RH/HC)	594	2.26%
គ្រូពេទ្យ 12 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 12 (RH/HC)	1371	5.21%
គ្រូពេទ្យ 13 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 13 (RH/HC)	2268	8.62%
គ្រូពេទ្យ 14 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 14 (RH/HC)	842	3.20%
គ្រូពេទ្យ 15 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 15 (RH/HC)	37	0.14%
គ្រូពេទ្យ 16 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 16 (RH/HC)	217	0.82%
គ្រូពេទ្យ 17 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 17 (RH/HC)	1801	6.84%
គ្រូពេទ្យ 18 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 18 (RH/HC)	262	1.00%
គ្រូពេទ្យ 19 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 19 (RH/HC)	1401	5.32%
គ្រូពេទ្យ 20 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 20 (RH/HC)	152	0.58%
គ្រូពេទ្យ 21 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 21 (RH/HC)	734	2.79%
គ្រូពេទ្យ 22 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 22 (RH/HC)	570	2.17%
គ្រូពេទ្យ 23 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 23 (RH/HC)	340	1.29%
គ្រូពេទ្យ 24 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 24 (RH/HC)	1601	6.08%
គ្រូពេទ្យ 25 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 25 (RH/HC)	1	0.00%
គ្រូពេទ្យ 26 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 26 (RH/HC)	205	0.78%
គ្រូពេទ្យ 27 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 27 (RH/HC)	498	1.89%
គ្រូពេទ្យ 28 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 28 (RH/HC)	2263	8.60%
គ្រូពេទ្យ 29 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 29 (RH/HC)	803	3.05%
គ្រូពេទ្យ 30 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 30 (RH/HC)	424	1.61%
គ្រូពេទ្យ 31 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 31 (RH/HC)	500	1.90%
គ្រូពេទ្យ 32 (នៅមន្ទីរពេទ្យបង្អែក/ម.ស) Dr 32 (RH/HC)	2432	9.24%
សរុបចំនួនពិគ្រោះជម្ងឺ Total Consultation	**26,324**	**100%**

មានតែអ្នកជំងឺដែលជាសមាជិករបស់អង្គការ ម.ព.ជ ទើបអាចជួបគ្រូពេទ្យបាន។ វា គឺជាប្រព័ន្ធណាត់ជួបពិគ្រោះ ដែលសម្របសម្រួលតាមរយៈបណ្តាញមិត្តអប់រំមិត្ត។ កន្លងមក អ្នកជំងឺបានបង់ថ្លៃអ្នកប្រើប្រាស់ទៅឲ្យមន្ទីរពេទ្យ និងបង់សំរាប់ជួលវេជ្ជបណ្ឌិតពិគ្រោះជំងឺ មិនមែនបង់ទៅឲ្យអង្គការម.ព.ជទេ។

Only patients who are member of MoPoTsyo can see the doctor. It is an appointment-based system, facilitated through the Peer Educator Network. So far the patients pay a user fee to the hospital and to hire consulted doctor, not to MoPoTsyo.

ខាងក្រោម ជាការគណនាថ្លៃចំនាយក្នុងឆ្នាំ២០១៨។ ពេលពាក់កណ្តាលព្រឹកចំនួន ៥៨២ដង មិនរួមបញ្ចូលនូវពេលធ្វើដំណើររបស់គ្រូពេទ្យធ្វើដំណើរទៅមកមន្ទីរពេទ្យគោលដៅឡើយ។ សម្រាប់ការប៉ាន់ស្មានលើ សមមូលនៃពេលពេញម៉ោង(FTE-Full Time Equivalent) របស់គ្រូពេទ្យត្រូវការ ដើម្បីធ្វើសកម្មភាពទាំងនេះ ពេលវេលាការធ្វើដំណើរគួរតែរាប់បញ្ចូល។ វាប្រហែលជាអាចច្រើនជាង១FTE ពេលណាត់ជួបគឺ ០.៥FTE។

Below is the cost calculation of 2018: the 582 half mornings does not include the “travel” time that is needed for the doctor to travel to and from the hospital. For estimating the Full Time Equivalent (FTE) of Doctors needed to do this activity, the traveling time should be added. We have not calculated the FTE for conducting all the consultations that include travel time. It may be more than 1 FTE. The session time is 0.5 FTE

ប៉ុន្តែការចំណាយ ចំពោះសំណងគ្រូពេទ្យលើការធ្វើដំណើរ និងការចំណាយពេលវេលាលើការធ្វើដំណើរ គឺបានត្រូវរាប់បញ្ចូល។ វាជា ជម្រើសល្អក្នុងការបង់ប្រាក់សម្រាប់ការធ្វើដំណើររបស់គ្រូពេទ្យម្នាក់ ជាជាងចេញសងសម្រាប់ការធ្វើដំណើររបស់អ្នកជំងឺ៤០នាក់។ ប្រសិនជាមធ្យម អ្នកជំងឺ៤០នាក់នឹងធ្វើដំណើរទៅមន្ទីរពេទ្យ វានឹងបន្ថែមយ៉ាងតិច ១លានរៀល (USD ២៥០) លើថ្លៃធ្វើដំណើររបស់ពួកគេ។ ដូចនេះ ដំណោះស្រាយ គឺមានប្រសិទ្ធភាព និងប្រហែលជាអាចជួយបន្ថយការចំណាយក្រៅហោរបៅ សម្រាប់ប្រជាជនដែលមានចំនួនច្រើន និងងាយរងគ្រោះ។

However, the cost of reimbursing the doctors for traveling and spending time traveling is included. It is of course better chioce to pay the doctor for his travel than to reimburse 40 patients for their travel. If on average 40 patients would have to travel to the provincial hospital, it would add at least 1,000,000 riels (USD 250) to their travel cost. So this solution is more efficient and probably helps reduce Out of Pocket Health Expenditure for a large and vulnerable population.

ក្នុងឆ្នាំ២០១៨ ការពិគ្រោះបានរៀបចំក្នុងមន្ទីរពេទ្យចំនួន១៣ នៃស្រុកប្រតិបត្តិចំនួន១២ ប្រៀបធៀបទៅនឹងឆ្នាំ២០១៧ ដែលការពិគ្រោះបានត្រូវធ្វើឡើងក្នុងស្រុកប្រតិបត្តិចំនួន១៤ និងមន្ទីរពេទ្យចំនួន១៤។ ដោយសារតែចំងាយទៅកាន់មន្ទីរពេទ្យបង្អែកខុសៗគ្នា នាំឱ្យការចំណាយសម្រាប់ការពិគ្រោះជំងឺនីមួយៗលើអ្នកជំងឺនីមួយៗ គឺខុសគ្នាខ្លាំងអាស្រ័យលើចំណាយធ្វើដំណើររបស់គ្រូពេទ្យ។

During 2018, consultations were done in 13 referral hospitals in 12 ODs, compared to 2017, when consultations were done in 14 ODs and 14 referral hospitals. Because of the varying distances to hospitals, cost per consultation per patient varies strongly, depending on doctor travelling expense.

តារាងទី8៖ ការងារពិគ្រោះជំងឺក្នុងឆ្នាំ២០១៨ Medical consultations in 2018

ឆ្នាំ ២០១៨ Year 2018	សរុប Total	ម.ប្រចាំឆ្នាំ/ទីតាំង Annual AVG/ per Location	ម.ប្រចាំខែ នៃ១៣ទីតាំង Monthly AVG of 13 Locations
1- ចំនួនអ្នកជម្ងឺដែលបានពិគ្រោះជម្ងឺ Nr of consultation	26,324	2,025	169
2- ថ្លៃ cost (Nr3+Nr4+Nr5+Nr6+Nr7+Nr8+Nr9+Nr10+Nr11 +Nr12+Nr13+Nr14)	$82,750.54	$6,365.43	$530.45
3- សេវាលើកទឹកចិត្តវេជ្ជ.មូលដ្ឋាន Incentive for Local Doctor	$26,665.25	$2,051.17	$170.93
4- សេវាលើកទឹកចិត្តប្រធានមន្ទីរពេទ្យបង្អែក Incentive for RH Director	$436.25	$33.56	$2.80
5- ថ្លៃសេវាហិរញ្ញប្បទានមន្ទីរពេទ្យបង្អែក User Fee	$21,289.25	$1,637.63	$136.47
6- សេវាមិត្តអប់រំមិត្ត Service for Peer Educator	$7,397.75	$569.06	$47.42
7- សេវាអ្នកគ្រប់គ្រងមិត្តអប់រំមិត្ត Service for ODPM	$9,135.00	$702.69	$58.56
8- សេវាលើកទឹកចិត្តក្រុមមិត្តអប់រំមិត្តចូលរួមវេនពិគ្រោះ Service for PE per session	$4,357.50	$335.19	$27.93
9- ថ្លៃចំណាយសំភារ: Materials	$10,070.51	$774.65	$64.55
10- ថ្លៃផ្ញើរសំភារ:/ឯកសារ Delivery of Materials and Documents	$458.75	$35.29	$2.94
11- ថ្លៃបោះពុម្ព ថតចំលង Copy and Printing	$1,040.98	$80.08	$6.67
12- ថ្លៃវេរប្រាក់ចូលធនាគារ Bank charge	$128.00	$9.85	$0.82
13- ថ្លៃបណ្តុះបណ្តាលវេជ្ជ.មូលដ្ឋាន Coach local doctor	1587.5	$122.12	$10.18
14- ចំនួនដងនៃការពិគ្រោះជម្ងឺ Nr of cons. session	589	45	3.8
15- ចំនួនអ្នកជម្ងឺក្នុងមួយដង Nr of patients per session	45		
ថ្លៃពិគ្រោះជម្ងឺម្នាក់ Cost per consultation	$3.14		

រូបភាពទី 19៖ ចំនួនការពិគ្រោះជំងឺតាមក្រុមអាយុ ដល់ឆ្នាំ២០១៨ Medical consultations by of 2018



រូបភាពទី 20៖ ការប្រើសេវាពិគ្រោះធៀបនឹងចំនួនសមាជិកតាមក្រុមអាយុ Use of medical consultation by age groups



តាមរបាយការណ៍ប្រើប្រាស់សេវា របស់អ្នកជំងឺលើសសម្ពាធឈាមគ្មានទឹកនោមផ្អែម គឺបានបង្ហាញច្បាស់ស្ទើតែគ្រប់តំបន់ អំពីចំនួនអ្នកមកទទួលយកសេវា នៅមានកម្រិតទាបនៅឡើយ។ តារាងខាងក្រោម គឺចង់បង្ហាញថា ទោះបីជាមានការរីកចម្រើនខ្លះៗកន្លងមក ប៉ុន្តែយើងត្រូវបន្តយកចិត្តទុកដាក់ ជំរុញឱ្យអ្នកជំងឺលើសសម្ពាធឈាមមកទទួលយកសេវាឱ្យបានកាន់តែច្រើនថែមទៀត។

Throughout the report the underutilization of services by non-diabetic hypertension patients is evident. In almost all the areas, the number of patients who received service is still low. The table below shows that cases number continued to decline and that we must continue to encourage more non-diabetic hypertension patients to receive medical consultation service.

តារាងទី ១៖ ការប្រើសេវាពិគ្រោះតាមប្រភេទជំងឺ តាមឆ្នាំនីមួយៗ ***Yearly use of medical consultation by type of diseases***

ការពិគ្រោះជម្ងឺដោយបណ្តាញមិត្តអប់រំមិត្តនៅកន្លែងផ្តល់សេវាសាធារណៈ Medical consultations facilitated by the Peer educator networks in the public services				
ឆ្នាំ Year	អ្នកជម្ងឺទឹកនោមផ្អែម គ្មានលើសសម្ពាធឈាម Diabetes, no hypertension	អ្នកជម្ងឺទឹកនោមផ្អែម និងលើសសម្ពាធឈាម Diabetes & Hypertension	អ្នកជម្ងឺលើសសម្ពាធឈាម គ្មានអ្នកជម្ងឺទឹកនោមផ្អែម Hypertension no Diabetes	សរុប Total
2007	42	92	0	**134**
2008	180	511	8	**699**
2009	370	800	15	**1,185**
2010	664	1,093	295	**2,052**
2011	1,709	3,045	1,355	**6,109**
2012	3,030	5,080	2,330	**10,440**
2013	4,006	5,265	2,466	**11,737**
2014	5,955	6,834	3,161	**15,950**
2015	7,009	6,784	3,157	**16,950**
2016	9,141	7,910	3,876	**20,927**
2017	9,851	8,365	3,463	**21,679**
2018	12,507	10,767	3,050	**26,324**
សរុប Total	**54,464**	**56,546**	**23,176**	**134,186**

ក្នុងឆ្នាំ២០១៨ អ្នកជំងឺទឹកនោមផ្អែមភាគច្រើនដែលបានទៅជួបគ្រូពេទ្យ គឺមិនមែនជាការទៅជួបលើកទី១ទេ គឺពួកគេទៅជួបតាមការណាត់របស់គ្រូពេទ្យ។ មូលដ្ឋានទិន្នន័យរបស់អង្គការ ម.ព.ជ បានកត់ត្រាឡើងវិញតាំងពីឆ្នាំ ២០០៧ បន្តបន្ទាប់មក។ ជាមធ្យមនៃការប្រើសេវានៃអ្នកជំងឺទឹកនោមផ្អែមទាំងនេះគឺ ៩។ ខណៈពេលដែលអ្នកជំងឺភាគច្រើនធ្លាប់មានបទពិសោធន៍ អ្នកជំងឺថ្មី ៣,២៨៣នាក់ បានមកជាលើកដំបូង ក្នុងឆ្នាំ២០១៨។

For most of the Diabetes patients in 2018 who went to see their Doctor it was not the first time they went for their doctor appoinments. MoPoTsyo database records go back to 2007. The average of these individual DM patients was 9 so while most have experience. 2,883 DM patients came for the first time and came only once in 2018.

រូបភាពទី 21៖ សមាមាត្រនៃការពិគ្រោះរបស់អ្នកជំងឺទឹកនោមផ្អែម ***Proportions of medical consultations by DM patients***



តារាងទី 10៖ ចំនួន និងភាគរយសមាជិកបានចុះឈ្មោះនៅបន្តប្រើសេវា ***Number and percentage of active members***

សមាជិកបន្តប្រើសេវាបណ្តាញមិត្តអប់រំមិត្ត នាដំណាច់ឆ្នាំ២០១៨ Actively Using PE network services by the end of 2018	**ចំនួនករណី**	**ភាគរយ**
អ្នកជំងឺទឹកនោមផ្អែម	14,629	80.1%
អ្នកជំងឺលើសសម្ពាធឈាម	3,645	19.9%
សរុបសមាជិកទាំងអស់នៅបន្តប្រើសេវា	18,274	100.0%

និន្នាការបង្ហាញថា ការជឿទុកចិត្តលើសេវាវេជ្ជសាស្ត្រគឺមានការរីកចំរើនជាបណ្តើរៗ ហើយនឹងអ្នកទឹកនោមផ្អែមជាច្រើនបានត្រៀមខ្លួនដើម្បីជួបជាមួយវេជ្ជបណ្ឌិត។

a) ក្នុងចំនោមអ្នកជំងឺទឹកនោមផ្អែម ភាគច្រើន ឥឡូវមានវេជ្ជបញ្ជា។

b) អ្នកជំងឺទឹកនោមផ្អែមទាំងនោះដែលមានវេជ្ជបញ្ជាទៅជួបគ្រូពេទ្យបានញឹកញាប់

ភាគបែងដែលសំខាន់បំផុត គឺជាចំនួនអ្នកជំងឺទឹកនោមផ្អែមដែលរស់នៅក្នុងតំបន់ (ទោះបីជាពួកគេបានចុះឈ្មោះ រឺក៏មិនបាន)។ ដូចនេះ ជាមូលដ្ឋានពួកយើងគួតែប្រើប្រាស់ប្រេវ៉ាឡង់ប៉ាន់ស្មានអ្នកទឹកនោមផ្អែមជាភាគបែង។ បែបនេះអាចទៅរួចជាមួយការស្ទង់មតិម្តងហើយម្តងទៀតយ៉ាងទៀងទាត់ ដូចជាការស្ទង់មតិរបស់STEP SURVEY២០១០ និង២០១៦។

តាមរយ:ការកត់ត្រាក្នុងប្រព័ន្ធទិន្នន័យរបស់យើងបានបង្ហាញ មិនមែនគ្រប់សមាជិកទាំងអស់បានប្រើប្រាស់គ្រប់សេវាបណ្តាញមិត្តអប់រំមិត្តនោះទេ។ យើងបានធ្វើការវិភាគតាមការប្រើសេវានីមួយៗ ដូចរូបខាងក្រោម។ វាមានបង្ហាញ សេវាឱសថបង្វិលទុនមានសមាជិកប្រើប្រាស់ច្រើនជាងគេគឺ ១៣,២១៩នាក់ បន្តបន្ទាប់មកទៀត មានសេវាតាមដានជាមួយមិត្តអប់រំមិត្ត ១១,៨៤៦នាក់ និងសេវាពិគ្រោះជំងឺមាន ៨,៧៧៦នាក់។ សេវាដែលមានចំនួនអ្នកប្រើប្រាស់តិចជាងគេ គឺសេវាមន្ទីរពិសោធន៍វេជ្ជសាស្ត្រគឺត្រឹមតែ ៥,០១៨នាក់។ អ្វីដែលគួរចាប់អារម្មណ៍ ចំនួនអ្នកប្រើសេវាបីរួមគ្នាតាមដានជាមួយមិត្តអប់រំមិត្ត ពិគ្រោះជំងឺ និងសេវាឱសថបង្វិលទុន មានចំនួនត្រឹមតែ ៥,១៣៥នាក់ប៉ុណ្ណោះ។

The trend shows that overall the trust in the medical services is gradually improving and that more diabetics are ready to meet the doctor:

a) Among diabetics a larger proportion now has a prescription

b) Those diabetics who have a prescription go more often to the doctor

The most relevant denominator would be the number of diabetes patients who live in the area. (whether they have been registered or not). So ultimately we should use the estimated prevalence of diabetes as the denominator. This becomes possible with regularly repeated surveys such as the STEP Survey (2010 and 2016).

